សមាគមបុគ្គលិកសិក្សាខ្មែរ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កម្មវិធីស្តារ
ជាមួយនឹង
ជំនួយសហគមន៍អឺរ៉ុប

# ទស្សនាវដ្តី

លេខ ១១

# គ្រូបង្រៀន



ខែ មេសា-ឧសភា-មិថុនា ឆ្នាំ ២០០០
ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ
១២៨ មហាវិថីព្រះនរោត្តម ( ភ្នំពេញ )
ទូរស័ព្ទ : ០២៣ ២១៦ ១៨៤
: ០១៥ ៩១៨ ១២៤




**សម្តេច ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា**

**ផ្ញើជូន**

**លោក យ៉ង់ ធី**

**ប្រធានសមាគមបុគ្គលិកសិក្សាខ្មែរ**

លោកប្រធានជាទីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ !

ខ្ញុំបានទទួលរួចហើយ នូវសេចក្តីរាយការណ៍ស្តីពីសកម្មភាពសមាគមបុគ្គលិកសិក្សាខ្មែរ ក្នុងរយៈពេល ៥ ឆ្នាំ ( ១៩៩៥-១៩៩៩ ) កន្លងមក ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះលោកប្រធានដែលបានខិតខំប្រឹងប្រែងយកអស់ពីកំលាំងកាយចិត្ត ធ្វើអោយសមាគមបុគ្គលិកសិក្សាខ្មែរបានឈានទៅរកការរីវឌ្ឍន៍ក្នុងស្ថានភាពមួយយ៉ាងល្អប្រសើរគួរអោយកត់សំគាល់ ។

ជោគជ័យដ៏ធំធេងនេះ គឺស្តែងអោយឃើញថា : សមាជិក សមាជិកានៃសមាគមបុគ្គលិកសិក្សាខ្មែរ បានរួមសហការគ្នាយ៉ាងស្អិតរមួត ដើម្បីទ្រទ្រង់សមាគមរបស់ខ្លួនអោយកាន់តែមានភាពរីកចំរើន និងល្បីល្បាញថែមទៀត ក្នុងទិសដៅចូលរួមចំណែកកសាងសង្គមជាតិ ក៏ដូចជាជួយសំរាលបន្ទុករបស់រាជរដ្ឋាភិបាលមួយផ្នែកផងដែរ ។

ជាអវសាន ខ្ញុំសូមសំដែងនូវការអបអរសាទរ និងកោតសរសើរជាអនេកចំពោះភាពជោគជ័យទាំងឡាយ ដែលសមាគមបុគ្គលិកសិក្សាខ្មែរទទួលបាន ហើយនិងសូមប្រសិទ្ធិពរជ័យ បវរសួស្តីមហាប្រសើរ កើតមានដល់លោកប្រធាន ព្រមទាំងសហការីទាំងអស់កុំបីឃ្លៀងឃ្លាតឡើយ ។

សូមលោកប្រធាន ទទួលនូវការស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០០០

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

# លិខិតថ្លែងអំណរគុណ

*****



## សូមគោរពជំរាបជូន

### ឯកឧត្តម សាយ ឈុំ ប្រធានគណៈប្រចាំការ

### គណៈកម្មាធិការកណ្តាលគណៈបក្សប្រជាជនកម្ពុជា

ក្នុងនាមគណៈកម្មាធិការនាយកនៃសមាគមបុគ្គលិកសិក្សាខ្មែរ និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណ និងដឹងគុណជាអនេកអនន្តចំពោះឯកឧត្តម ដែលបានឧបត្ថម្ភគាំទ្រសមាគមនូវទឹកប្រាក់ចំនួនបីលានរៀល (៣.០០០.០០០៛) ។

កាយវិការដ៏ប្រសើរថ្លៃថ្លានេះជាសក្ខីកម្ម នៃសមានចិត្តជាប់ជំពាក់យ៉ាងជ្រាលជ្រៅរបស់ឯកឧត្តមចំពោះសមាគមបុគ្គលិកសិក្សាខ្មែរ ។

សមាជិក សមាជិកានៃសមាគមទាំង ៧៩.៨៥១ នាក់ មិនអាចបំភ្លេចឧបការគុណនេះបានឡើយ ។

សូមឯកឧត្តម ទទួលយកឋានៈជាសមាជិកកិត្តិយសនៃសមាគមយើងខ្ញុំ ។

សូមពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ចូលមានដល់ឯកឧត្តមកុំបីឃ្លៀងឃ្លាតឡើយ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០០

ជ. គណៈកម្មាធិការនាយក

ហត្ថលេខា និង ត្រា

**យ៉ង់ ធី**

# ជំនួបសំណេះសំណាលជាមួយនិស្សិតជប៉ុន

* * * * *

កាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០០ វេលាម៉ោង ៨:៣០ព្រឹក នៅក្នុងសាល "ទស្សនាវដ្តីគ្រូបង្រៀន" នៃមហាវិទ្យាល័យគរុកោសល្យ លោក យ៉ង់ ធី ប្រធានគណៈកម្មាធិការនាយកនៃស.ប.ស.ខ រួមដោយលោក យស់ អ៊ាង និងលោក កៅ ជឿន សមាជិក ស.ប.ស.ខ បានទទួលគណៈប្រតិភូនិស្សិតជប៉ុន ២៥នាក់ (ប្រុស-ស្រី) ដឹកនាំដោយលោកស្រី **OSANAI MIEKO** ប្រធានអង្គការ **J.H.P** ដែលជាអង្គការជួយសាងសង់អាគារសិក្សានៅកម្ពុជា ។

និស្សិតទាំង ២៥នាក់នេះ មានបំនងស្វែងយល់ពីការអប់រំនៅកម្ពុជា និងពីសមាគមបុគ្គលិកសិក្សាខ្មែរ ។ ដើម្បីបំពេញបំនងនេះ លោក យ៉ង់ ធី បានឧទ្ទេសនាមជូនភ្ញៀវពីប្រព័ន្ធអប់រំនៅកម្ពុជាតាំងពីសម័យបុរាណដល់សម័យបច្ចុប្បន្ន ការអភិវឌ្ឍន៍នៃការអប់រំ និងការកែទំរង់ផ្សេង ៗ ។

ក្រោយពីការឧទ្ទេសនេះ និស្សិតបានលើកសំនួរជាច្រើន ដើម្បីសុំបំភ្លឺបន្ថែម ។

ដោយពេលវេលាមិនអនុញ្ញាតបន្ត ដើម្បីឧទ្ទេសពីសមាគមបុគ្គលិកសិក្សាខ្មែរ លោក យ៉ង់ ធី បានបញ្ចប់ការសំនេះសំនាលនេះដោយបានជូនដល់និស្សិតគ្រប់គ្នានូវ :

**១- សៀវភៅ "ការអប់រំនៅកម្ពុជា" ផ្សាយចេញពីនាយកដ្ឋានផែនការ ក្រសួងអប់រំ យុវជន និង កីឡា**

**២- កំរងអត្ថបទ ស្តីពីសមាគមបុគ្គលិកសិក្សាខ្មែរសរសេរជាបីភាសា ខ្មែរ-បារាំង-អង់គ្លេស**

ចំពោះលោកប្រធានគណៈប្រតិភូនិស្សិត លោក យ៉ង់ ធី បានជូន " រូបចំលាក់អប្សរា " ដើម្បីជាអនុស្សាវរីយ៍ ។








# អនាគតនៃការអប់រំនៅកម្ពុជា

~~~

ដើម្បីស្វែងយល់ពីការអប់រំនៅកម្ពុជា និងកំណត់ទិសដៅអប់រំទៅអនាគតអោយបានច្បាស់លាស់ បុគ្គលិកសិក្សាដែលជាអ្នកទទួលភារកិច្ចបង្រៀនផង អប់រំផងនោះ គួរតែយល់អោយបានល្អិតល្អន់នូវ :

១- ស្ថានភាពអប់រំនៅប្រទេសរបស់ខ្លួននាពេលបច្ចុប្បន្ន និងស្ថានភាពសង្គមសេដ្ឋកិច្ចជាមុនសិន ព្រោះវាជាកត្តាកំណត់នៃការអភិវឌ្ឍន៍សង្គមវប្បធម៌របស់ប្រទេស ។

២- ស្ថានភាពអប់រំនៅក្នុងតំបន់គឺនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ និងនៅលើពិភពលោក ដើម្បីយល់ដឹងពីនិន្នាការ និងអភិវឌ្ឍន៍វិស័យអប់រំ ។

ការយល់ដឹងលើចំនុចទាំងពីរនេះ នាំអោយយើងមានចក្ខុវិស័យទូលាយអាចឆ្លុះបញ្ចាំងតំរូវការរបស់ប្រទេសកម្ពុជាក្នុងវិស័យអប់រំ និងបណ្តុះបណ្តាល និងកង្វះខាត ។ តែជាអកុសល គ្រូយើងនាបច្ចុប្បន្ននេះ ដែលបានបណ្តុះ-បណ្តាលក្រោយឆ្នាំ ១៩៧៩ មិនបានចេះភាសាបរទេសជ្រៅជ្រះឡើយ ។ ឯកសារអប់រំនិយាយពីការអប់រំនៅក្នុងតំបន់ និងនៅប្រទេសលោកខាងលិច ច្រើនសរសេរជាភាសាអង់គ្លេស បារាំង អេស្ប៉ាញ ។ តើធ្វើម្តេចនឹងយល់បាន បើគ្រូយើងមិនបានចេះភាសាអស់ទាំងនេះ ? ។ មធ្យោបាយមានតែមួយ គឺបង្កើតក្រុមអ្នកបកប្រែភាសា ដើម្បីអោយគ្រូយើងបានក្រេបជញ្ជក់នូវចំណេះដឹងថ្មី ពត៌មានថ្មី ផ្សាយចេញពីប្រទេសអាស៊ីយើងនេះ ។

ឥឡូវនេះ ខ្ញុំសូមលោកគ្រូ - អ្នកគ្រូ ងាកមកពិចារណាពីទំនាស់ប្រឈមមុខនឹងការវិវឌ្ឍន៍វិស័យអប់រំនៅកម្ពុជា ។ តើកត្តាអ្វីខ្លះដែលប្រឈមមុខនឹងដំណើររីកចំរើននៃវិស័យនេះ ?

ចំពោះបញ្ហានេះ ខ្ញុំសូមលោក-អ្នកអប់រំទូទាំងប្រទេស មេត្តាពិនិត្យអោយបានស៊ីជំរៅនូវស្ថានភាពបច្ចុប្បន្ននៃប្រទេសយើងទៅលើចំណុចបី ដូចខាងក្រោម :
~~~

ក- នយោបាយ Le politique [១]

ខ- សង្គមសេដ្ឋកិច្ច Le socio-économique

គ- សង្គមវប្បធម៌ Le socio-culturel

## ក/ នយោបាយ

ប្រទេសកម្ពុជាទើបនឹងឆ្លងផុតពីរបបប្រល័យពូជសាសន៍ ដែលអូសបន្លាយអស់រយៈពេលជាង ២០ ឆ្នាំមកហើយ ។ សន្តិភាពកើតមានលើទឹកដីកម្ពុជាក្រោយពីមហិច្ឆតាដ៏ខ្មៅងងឹតនៃអ្នកលោភលន់អំណាច ត្រូវសាបរលាបនាឆ្នាំ ១៩៩៨ ។ សន្តិភាពមានពិតហើយខាងផ្នែកអាវុធសង្គ្រាម (conflit armé) ។ ក៏ប៉ុន្តែ រដ្ឋាភិបាលត្រូវប្រឈមមុខនឹងសន្តិសុខសង្គម (sécurité sociale) សណ្តាប់ធ្នាប់សង្គម (ordre social) និងភាពហឹង្សា (violence) មានលួច ប្លន់ កាប់ចាក់ សំលាប់គ្នាជាដើម ។ គ្រប់ទំព័រកាសែតក្នុងស្រុក បានលាតត្រដាងអំពីអំពើកាចសាហាវយង់ឃ្នងគ្រប់បែបយ៉ាងដែលគួរអោយអាម៉ាស់ ។ រដ្ឋាភិបាលមានគោលនយោបាយសមស្របប្រកបដោយគតិបណ្ឌិត បំបាត់ជាបណ្តើរៗនូវអំពើអសកម្មនៃសង្គម និងបំផុសចិត្តគំនិតយោគយល់គ្នា ស្រលាញ់រាប់អានគ្នាជាបងជាប្អូន ។ ក៏ប៉ុន្តែជាអកុសលពលរដ្ឋមួយចំនួនប្រើហឹង្សាឥតមានធម៌សន្តោសប្រណីគ្នា ។ សង្គមប្រេះឆាដោយអ្នកប្រកាន់បក្សពួកមានចិត្តមិនទោរទន់រកគ្នា ។

## ខ/ សង្គមសេដ្ឋកិច្ច

ប្រទេសកម្ពុជា ជាប្រទេសកសិកម្ម ។ ពីរភាគបី (២/៣) នៃកំលាំងពលកម្មស្ថិតនៅក្នុងវិស័យកសិកម្ម ។ ផ្អែកលើមូលដ្ឋាននៃការគណនាបន្ទាត់ក្រីក្រ គេបានដឹងថា ៣០% នៃប្រជារាស្ត្រជាអ្នកក្រីក្រ [២] ។

តាមស្ថិតិ ប្រជារាស្ត្រទីទាល់ក្ររកមិនបានប្រាក់ ១ ដុល្លារផងក្នុង១ ថ្ងៃ ។ ប្រាក់ចំណូលពន្ធអាករផ្សេងៗ ដែលជាមូលដ្ឋាននៃថវិកាជាតិមានកំរិតទាប ។

## គ/ សង្គមវប្បធម៌

ឥទ្ធិពលនៃទុគ៌តភាព និងអវិជ្ជាបានជំរុញ :

១/- អត្រាកំនើនប្រជារាស្ត្រប្រចាំឆ្នាំអោយឡើងដល់ ២.៤៩% [៣] ។ បានសេចក្តីថា ក្នុងមួយឆ្នាំៗ ប្រជារាស្ត្រកើនជាងពីរនាក់ក្នុង ១០០ នាក់ ។

---

១- Politique (au masculin) មានន័យពីរ : ១- អ្នកនយោបាយ គឺអ្នកកំពុងបំពេញការងារនយោបាយ ។ ២- អ្វីដែលទាក់ទិននឹងរដ្ឋាភិបាល និងគោលការណ៍ធំៗនៃទង្វើរបស់រដ្ឋាភិបាល ។

២-ស្រង់ចេញពីផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ ឆ្នាំលើកទី ១ (១៩៩៦-២០០០) នៃក្រសួងផែនការ ។

៣-លទ្ធផលជំរឿនសរុបចុងក្រោយ (ក្រសួងផែនការ-វិទ្យាស្ថានជាតិស្ថិតិ) ។

ឧទាហរណ៍ ៖ ក្នុងឆ្នាំ ១៩៩៨ ប្រជារាស្ត្រសរុបមានចំនួន ១១.៤៣៧.៦៤៦នាក់ ។ ដល់ឆ្នាំ ២០០៣ គឺរយៈពេល ៥ឆ្នាំ ប្រជារាស្ត្រកើនឡើង (តាមរបៀបងាយគិត) ៖

$$\frac{2,49 \times 11.437.646}{100} \times 5 = 1.423.987$$ នាក់ថែមទៀត ។

គឺដោយសារតែកំនើនឥតមានអ្វីទប់នេះឯងហើយ ទើបរាជរដ្ឋាភិបាលត្រូវប្រឈមមុខនឹងកង្វះខាតថ្នាក់រៀន ខ្វះខាតគ្រូបង្រៀន ខ្វះខាតសំភារៈឧបទេស -ល-។ ដូចយើងបានឃើញស្រាប់ហើយថា សព្វថ្ងៃនេះ សិស្សរៀននៅសាលាត្រូវចែកជាពីរក្រុម ។ ក្រុមទី ១ រៀននៅពេលព្រឹក ក្រុមទី ២ រៀននៅពេលរសៀល ហើយផ្លាស់ប្តូរក្រុមមួយខែម្តង។ ។ នៅខេត្ត-ក្រុងខ្លះ សិស្សត្រូវបានចែកជាបីក្រុម គឺរៀនក្នុងមួយថ្ងៃបីពេល ហើយមួយពេល។ មានសិស្សពី ៦០ ទៅ ៧០នាក់ ។ បញ្ហាកំនើនកុមារដល់វ័យសិក្សា គឺជាបញ្ហាចោទចំពោះការសាងសង់ថ្នាក់រៀនមិនចេះចប់ ។ ការបណ្តុះបណ្តាលគ្រូបង្រៀនត្រូវធ្វើរៀងរាល់ឆ្នាំ ។

២/- ភាពក្រខ្សត់នៅតែធ្ងន់ធ្ងរ និងត្រាំត្រែងពីមួយឆ្នាំទៅមួយឆ្នាំ ។ វាទាក់ទងនឹងជីវភាពរស់នៅរបស់ឪពុកម្តាយសិស្ស ដែលធ្វើអោយសិស្សមួយចំនួននៅជនបទ បោះបង់ការសិក្សា ទាក់ទងនឹងជីវភាពគ្រូបង្រៀនថែមទៀត ។

៣/- សុខភាពមិនបរិបូរណ៍ ស្ថានភាពអាហារូបត្ថម្ភពុំសមស្រប លក្ខខ័ណ្ឌរស់នៅពុំមានអនាម័យ ។

វាជាក្រិត្យក្រមទៅហើយ ដែលគេពោលថា ជំងឺច្រើនតែយាយីអ្នកក្រ ដោយអ្នកក្រ ហូបមិនឆ្អែត ម្ហូបអាហារពុំមានជីវជាតិគ្រប់គ្រាន់ ។ ជំងឺរាករូស គ្រុនចាញ់ គ្រុនពោះវៀន ជំងឺគ្រុនឈាម ជាមូលហេតុចំបងនៃការបាត់បង់ជីវិតរបស់កុមារ ។

ក្នុងបរិបទរួមនៃស្ថានភាព (ចំនុច ខ និង គ) រដ្ឋមិនមានលទ្ធភាពផ្តល់ថវិកាសំរាប់សាងសង់អគារសិក្សាអោយបានគ្រប់គ្រាន់នៅឡើយទេ និងមិនមានលទ្ធភាពផ្តល់ប្រាក់បៀវត្ស អ្នកបង្រៀនអោយមានជីវភាពសមរម្យឡើយ ។

ម្យ៉ាងទៀត ភាពអត់ការងារធ្វើបានចោទជាបញ្ហាដ៏ធ្ងន់ធ្ងរចំពោះសង្គម ។ និស្សិតផ្នែកវិទ្យាសាស្ត្រសង្គម វិទ្យាសាស្ត្រពិត (ធម្មជាតិ) និងវិទ្យាសាស្ត្របច្ចេកទេស ពិបាករកការងារធ្វើ ដោយរោងចក្រ សហគ្រាសរដ្ឋ ត្រូវបានជួល រឺលក់ទៅអោយនាយទុន រឺទុកចោលឥតមានសកម្មភាពផលិត ។ នាយទុនដែលស្ម័គ្រចិត្តមកវិនិយោគទុននៅកម្ពុជា គេប្រាថ្នាចំនេញ និងប្រមូលទុនអោយបានលើសដើម ។ វិស្វករ អ្នកបច្ចេកទេសមធ្យម និងកម្មករខ្មែរក្នុងស្រុកមិនងាយបានចូលបំរើការ ព្រោះគេយល់ថា អ្នកបច្ចេកទេសរបស់យើងមិនសូវមានបទពិសោធន៍ និងចំនេះដឹងនៅមានកំរិត ។ ទោះបីបានចូលធ្វើការ ប្រាក់បៀវត្សក៏តិចដែរ ពិបាកនឹងចិញ្ចឹមជីវិត ។ ដោយសារបញ្ហាខាងលើនេះ ទំនាស់បានធ្លាក់មកលើនិស្សិតដែលទើបចេញពីសាកលវិទ្យាល័យ មហាវិទ្យាល័យនានា និងសិស្សដែលមានសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ ។ តាមធម្មតា អ្នកដែលមានសញ្ញាប័ត្រជាបរិញ្ញាប័ត្រ ជាវិស្វករ រឺអ្នកដែលមានសញ្ញាប័ត្រមធ្យម

សិក្សាការិត ២ មិនងាយនឹងទៅប្រកបការងារកសិកម្មទេ ដោយគេយល់ថា គេបានតស៊ូ និងបានចំនាយទ្រព្យសម្បត្តិអស់ជាច្រើនក្នុងការរៀនសូត្រ ។

ជាការសន្និដ្ឋានរួម និងតាមការត្រិះរិះពិចារណាទៅលើស្ថានភាពសង្គម-សេដ្ឋកិច្ច-និងវប្បធម៌នៃប្រទេសកម្ពុជានាពេលបច្ចុប្បន្នកាលនេះ ខ្ញុំសូមមានមតិ មិនមែនប្រកបដោយទុទិដ្ឋិនិយមទេ តែជាមតិឆ្លុះបញ្ចាំងការពិត ។

ជារៀងរាល់ឆ្នាំ នៅថ្ងៃបិទសន្និបាតអប់រំ លោករដ្ឋមន្ត្រីក្រសួងអ.យ.ក តែងតែបូកសរុបការងារសន្និបាត និងដាក់ទិសដៅអនុវត្ត ដើម្បីអោយលោកអ្នកបង្រៀន វិះរកមធ្យោបាយកែលំអចំនុចបី គឺ :

១- បរិមាណ **quantité**

២- គុណភាព **qualité**

៣- ប្រសិទ្ធភាព **efficacité**

ពិតមែនហើយ ការដាក់ទិសដៅនេះ ជាភារកិច្ចនៃថ្នាក់ដឹកនាំស្ថាប័នអប់រំ តែការអនុវត្តន៍ដាក់ស្តែងទទួលលទ្ធផលសំរេចបានក៏រិតណានោះ វាមិនមែនជាភារកិច្ចរបស់អ្នកអប់រំតែម្នាក់ឯងទេ គឺជាភារកិច្ចនៃប្រជាពលរដ្ឋគ្រប់រូប ដែលត្រូវរួបរួមកំលាំងកាយ ចិត្ត ចំពោះបុព្វហេតុអប់រំ ។ ខ្ញុំអាចសន្និដ្ឋានថា ប្រទេសក្រខ្សត់ ដូចប្រទេសកម្ពុជាយើងសព្វថ្ងៃ មិនអាចមានការអប់រំប្រកបដោយគុណភាពបានឡើយ ។ រីឯបរិមាណក៏ដូចគ្នាដែរ ។ ការបោះបង់ការរៀនសូត្រដោយប្រការណាមួយ ការត្រួតថ្នាក់ មានមូលហេតុជាក់ច្បាស់ណាស់ គឺទុគ៌តភាព ។ ប្រសិទ្ធភាពនៃប្រព័ន្ធសិក្សាមិនមានឡើយ ។ ខ្ញុំសូមមិនរំលឹកឡើងវិញទេ ពីមូលហេតុនៃកង្វះគុណភាពអប់រំ ។ អ្នកបង្រៀន បានជ្រាបអស់ហើយ ពីកត្តាកំនត់គុណភាព និងប្រសិទ្ធភាពអប់រំ ។ សូមពិចារណា និងស្វែងយល់ពីតថភាពនេះ ដើម្បីចៀសវាងពំនោលឥតប្រយោជន៍ ឥតខ្លឹមសារ ។ គេនាំគ្នាពោលថា ការអប់រំសព្វថ្ងៃមិនមានគុណភាពបន្តិចសោះ តែគេមិនបានវិភាគពីមូលហេតុដែលនាំអោយមានកង្វះខាតនេះ ។

ចំពោះការងារអប់រំ រាជរដ្ឋាភិបាលបច្ចុប្បន្នបានយកចិត្តទុកដាក់ជាទីបំផុត ។ ក៏ប៉ុន្តែធ្វើដូចម្តេចនឹងបានដូចសេចក្តីប្រាថ្នា ។ អច្ឆរិយបុគ្គល រឺទេវតាចុះពីលើមេឃ ក៏មិនអាចប្រែក្លាយប្រទេសខ្មែរ នាំអោយសម្បូរហូរហៀរនូវភោគទ្រព្យក្នុងមួយប៉ប្រិចភ្នែកបានឡើយ ។ យើងត្រូវតែរួមកំលាំងគ្នាកសាងប្រទេសជាតិ ដោយឈរលើគំនិតស្នេហាជាតិ មនសិកាជាតិ ដើម្បីកាត់បន្ថយភាពក្រីក្រ និងកាត់បន្ថយអតុល្យភាពក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។ យើងត្រូវតែគាំទ្រគោលនយោបាយរដ្ឋាភិបាលសេដ្ឋកិច្ច ដែលកំពុងបោះជំហានទៅមុខ ដោយក្តីសង្ឃឹម ។

ដូចនេះ អនាគតនៃការអប់រំ និងបណ្តុះបណ្តាលធនធានមនុស្ស ចំណុះទាំងស្រុងទៅលើសង្គមសេដ្ឋកិច្ច-វប្បធម៌ ។ យើងមិនអាចប្រៀបផ្ទឹមទៅនឹងប្រទេសជឿនលឿនបានទេ ។

យ៉ង់ ធី

# បណ្តុះបណ្តាល មនុស្ស ពលរដ្ឋ ពលករ

## *Former l'homme, le citoyen, le travailleur*

------*------

ជាទូទៅ គ្រប់ប្រទេសលើសកលលោក តែងតែមានទស្សនៈអប់រំ (philosophie de l'éducation) និង គោលនយោបាយអប់រំ (politique de l'éducation) ស្របទៅនឹងកម្មវិធីនយោបាយរដ្ឋាភិបាលជាដរាប ។ នៅប្រទេសកម្ពុជាយើងក៏ដូច្នេះដែរ ។ គោលដៅអប់រំដែលបានលើកឡើងក្នុងកម្មវិធីសិក្សា រឺក្នុងសៀវភៅអប់រំ ទោះជាគេសរសេរបានវែងយ៉ាងណាក៏ដោយ ក៏អាចបង្រួញមកត្រឹមតែពាក្យបីម៉ាត់ គឺបណ្តុះបណ្តាលរូម[១] តែម្តងក្នុងសិស្សម្នាក់អោយបាននៅពេលអនាគតជា :

- មនុស្សល្អ
- ពលរដ្ឋល្អ
- ពលករល្អ

( ***Former à la fois l'homme, le citoyen et le travailleur*** )

យើងប្រាថ្នាចង់បានមនុស្សល្អ ពលរដ្ឋល្អ និង ពលករល្អ នៅក្នុងសង្គមនីមួយៗ ។ ក៏ប៉ុន្តែ គោលដៅនេះ មិនអាចសំរេច ១០០% ទៅតាមការចង់បាននោះទេ ពីព្រោះមនុស្សកើតមកមានអត្តចរិតដើមខុសៗគ្នា ។ យើងចង់បានក្រុមមនុស្ស ដែលព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូនៃយើង ទ្រង់បានចាត់ថ្នាក់រួចហើយ គឺមនុស្សទេវតា ។ គ្រួសារ សាលារៀន សង្គម សុទ្ធតែមានបំនងប្រាថ្នាដូចគ្នា គឺអប់រំកូនចៅយ៉ាងណាអោយបានទៅជាមនុស្សល្អ ។ ក្រសួងអប់រំ យុវជន និង កីឡា ដែលជាស្ថាប័នរដ្ឋ បានខិតខំរៀបចំរចនាសម្ព័ន្ធសិក្សាអប់រំ និងបានកំនត់បេសកកម្ម ដែលអង្គភាពនីមួយៗត្រូវបំពេញអោយបានសំរេច ។

សូមលោកគ្រូ-អ្នកគ្រូ ពិចារណាឡើងវិញជាមួយខ្ញុំពីអង្គការលេខរបស់ក្រសួង អ.យ.ក ( សូមអានទស្សនាវដ្តីគ្រូបង្រៀនលេខ ៩ ទំព័រ ១៤) ។

---

(១)- បណ្តុះ អប់រំ បង្ហាត់បង្រៀន ហាត់ពត់លត់ដំ ជាវេវចនៈ ។

ខ្ញុំសូមគូសគំនូរបំប្រួញដូចខាងក្រោមនេះ :




តាមគំនូសបំប្រួញនេះ យើងឃើញថា បេសកកម្មអប់រំ ដឹកនាំនិងគ្រប់គ្រង របស់ក្រសួង អ.យ.ក មានមុខព្រួញបាញ់ឆ្ពោះរួមគ្នាទៅការអប់រំមនុស្ស ពលរដ្ឋ និងពលករ តែប៉ុននោះ ។

គោលដៅដ៏សំខាន់នេះ ត្រូវបានកំនត់ជាយូរយារណាស់មកហើយនៅប្រទេសបារាំង គឺតាំងពីលោក Jules Ferry ឡើងកាន់តំណែងជារដ្ឋមន្ត្រីក្រសួងសិក្សាសាធារណៈ ( Instruction publique ) នៅឆ្នាំ ១៨៧៩-១៨៨៣ ។ មកដល់បច្ចុប្បន្នកាល បារាំងនៅតែរក្សាទុកគោលដៅនេះដដែល ។ គេគ្រាន់តែកែលំអលក្ខណៈការងារចាំបាច់ និងរិះរកមធ្យោបាយថ្មីៗ ដើម្បីធ្វើអោយសុក្រឹតវិទ្យាសាស្ត្រអប់រំបច្ចុប្បន្ន ។ ប្រទេសកម្ពុជាសំរេចយកគោលដៅនេះ ជាត្រីវិស័យរហូតមកដល់សព្វថ្ងៃនេះ ។

នៅខែវិច្ឆិកា ឆ្នាំ ១៩៩១ លោក Federico Mayor អតីតអគ្គនាយកអង្គការ យូណេស្កូ ត្រូវបានចាត់ដោយមហាសន្និបាតអោយរៀបចំគណៈកម្មការអន្តរជាតិមួយ ទទួលបន្ទុកគិតពិចារណាអំពីការអប់រំ និងការបង្រៀន-រៀនសំរាប់ស.វ ទី ២១ ។ លោក Federico Mayor បានអញ្ជើញលោកហ្សាក់ដឺល័រ Jacques Delors អតីតប្រធានសហគមន៍អឺរ៉ុប ធ្វើជាប្រធានគណៈកម្មការនេះ ដោយមានសមាជិកចំនួន ១៤ នាក់ មកពីគ្រប់តំបន់នៃពិភពលោក

ហើយមានទស្សនៈវិស័យវប្បធម៌ និងវិជ្ជាជីវៈប្លែកៗគ្នា ។

គណៈកម្មការអន្តរជាតិនេះ ត្រូវបានបង្កើតជាផ្លូវការនៅដើមឆ្នាំ ១៩៩៣ ហើយបានធ្វើការក្នុងរយៈពេល ៣ ឆ្នាំ (ដើមឆ្នាំ ១៩៩៣ រហូតដល់ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៩៦ ដែលជាថ្ងៃអនុម័តរបាយការណ៍ជូនទៅអង្គការយូណេស្កូ) ។

ក្នុងចិរវេលាដ៏វែងនេះ គណៈកម្មការអន្តរជាតិបានគិតពិចារណាគ្រប់ជ្រុងជ្រោយ និងល្អិតល្អន់អំពីការអប់រំ និងការបង្ហាត់បង្រៀនសំរាប់ ស.វ ទី ២១ នៅលើពិភពលោកទាំងមូល ។ គណៈកម្មការបានធ្វើរបាយការណ៍មួយ រួមមាន ៣១២ ទំព័រ ដើម្បីជូនអង្គការយូណេស្កូ ដែលបានបោះពុម្ពផ្សាយក្នុងឆ្នាំ ១៩៩៦ ។

នៅក្នុងសេចក្តីផ្តើម លោក Jacques Delors បានសរុបមតិរបស់គណៈកម្មការ ហើយជាការសន្និដ្ឋានបានយករឿងល្បើកមួយរបស់កវី La Fontaine (១) ដែលមានចំនងជើងថា : " Le laboureur et ses enfants " ប្រែថា " កសិករ និង កូនគាត់ " ។

កសិករនៅពេលជិតស្លាប់បានផ្តាំកូនថា : " ចូរកូនកុំលក់ដីកេរដែលជីដូនជីតាទុកអោយយើងរាល់គ្នា ព្រោះកំនប់ទ្រព្យមួយលាក់ទុកនៅក្នុងដីកេរនោះ " ។

តាមបណ្តាំនេះ យើងអាចសន្និដ្ឋានថា មុនអនិច្ចកម្ម ឪពុកប្រកបដោយគតិបណ្ឌិតបានប្រាប់កូនអោយយល់ថា " ការអប់រំជាកំនប់ទ្រព្យ " :

**L'EDUCATION**

**UN TRESOR EST CACHÉ DEDANS**

យើងគួរត្រលប់មកពិចារណាលើរបាយការណ៍របស់គណៈកម្មការអន្តរជាតិ ដែលបានសិក្សាពីការអប់រំសំរាប់ ស.វ ទី ២១ ។ តើចិន្តបណ្ឌិតទាំង ១៥ នាក់ (រាប់ទាំងប្រធាន) និងអ្នកផ្តល់មតិយោបល់ជាច្រើនទៀតមានទស្សនៈយ៉ាងណា ?

ដោយបានខិតខំស្វែងយល់ពីខ្លឹមសារនៃរបាយការណ៍របស់គណៈកម្មការអន្តរជាតិ ខ្ញុំសូមពាំនាំមតិយោបល់សំខាន់ៗមកជូនជ្រាបដូចតទៅ ។ ជាដំបូង គណៈកម្មការបានវិភាគស្ថានភាពទូទៅ នៃពិភពលោក (នយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌) នាចុងសតវត្សទី ២០ ។ គណៈកម្មការបានសង្កេតឃើញថា ក្រោយពីសង្គ្រាមត្រជាក់បានផុតរលត់ទៅ នាចុងឆ្នាំ ១៩៨៩ ប្រទេសមួយចំនួនរើបំរះទៅរកលទ្ធិជាតិនិយមរៀងៗខ្លួន គឺ :

(១) - ឡាហ្វុងតែន (១៦២១-១៦៩៥) កវីបារាំង ស.វ ទី ១៧ ។

១- បំបែកខ្លួនពីអតីតប្លុកកុំមុយនីស្ត ។ ឧទាហរណ៍ : សង្គ្រាមនៅយូហ្គូស្លាវី និង ឆេចឈ្នី -ល-។

២- ទាមទារឯករាជ្យភាពនៃកុលសម្ព័ន្ធនៅទ្វីបអាហ្វ្រិច ស្រីលង្កា ឥណ្ឌូនេស៊ី -ល- បង្កើតបានជាសង្គ្រាមស៊ីសាច់ហុតឈាមគ្នារហូតមកដល់សព្វថ្ងៃនេះ ។

ម្យ៉ាងទៀត ភាពជ្រួលច្របល់នាំអោយមានកង្វល់ចិត្ត ភាពតានតឹងគ្រប់បែបយ៉ាង ដោយសារអយុត្តិធម៌ក្នុងសង្គម និងក្នុងវិស័យសេដ្ឋកិច្ច ភាពតានតឹងលេចចេញពីសកលកម្មនៃការប្ដូរទូទាត់សេដ្ឋកិច្ច និងបច្ចេកទេសគមនាគមន៍ (Mondialisation des échanges économiques et des techniques de communication ) ភាពតានតឹងរវាងស្មារតី និងសំភារៈ នាំអោយគណៈកម្មការមូលមតិគ្នា ស្នើអោយពិភពលោកទាំងមូលងាកមករកលទ្ធិ មនុស្សនិយម (Humanisme) ។ បានសេចក្ដីថា ងាកមកអប់រំមនុស្សដែលរស់នៅលើលោកនេះ អោយប្រែក្លាយជាមនុស្សល្អ ស្គាល់តំលៃមនុស្ស ចេះគោរពអ្នកដទៃ ចេះស្រលាញ់គ្នាទៅវិញទៅមក ចេះស្រលាញ់មនុស្សដូចគ្នា គឺមិនប្រកាន់ពូជសាសន៍ -ល-។ តើមានមធ្យោបាយអ្វីយកមកប្រើ ដើម្បីជំរុញការអភិវឌ្ឍន៍ធនធានមនុស្សអោយកាន់តែប្រសើរ ដែលនាំអោយចេះជួយកាត់បន្ថយទុគ៌តភាព មិនបែងចែកវណ្ណៈ មិនគាបសង្កត់ជិះជាន់គ្នា យកមនុស្សដូចគ្នាធ្វើជាមិត្ត ។ គណៈកម្មការសំនូមពរអោយយកការអប់រំជាមធ្យោបាយ ដើម្បីបំផុសឧត្តមគតិប្រជាធិបតេយ្យ និងបំផុសភាពជិតស្និតរវាងសង្គមនានា នៅ ស.វ ទី ២១ ខាងមុខ ។ ខ្ញុំសូមលើកទស្សនៈពីរ របស់គណៈកម្មការដែលខ្ញុំយល់ថាមានសារៈសំខាន់ គឺ :

១- ការអប់រំពេញមួយជីវិត " L'éducation tout au long de la vie " ដើម្បីដោះស្រាយសភាពការណ៍ថ្មីៗ ដែលកើតមាននៅក្នុងឆាកជីវិតផ្ទាល់ និងជីវភាពការងារ ។ ម្យ៉ាងទៀត ការអប់រំនេះ ទាមទារអោយមានការយល់ដឹងពីភាពផ្សេងៗនៃសង្គមមនុស្ស អោយមានការយោគយល់គ្នាទៅវិញទៅមក និងមានការផ្លាស់ប្ដូរអាកប្បកិរិយា និងឥរិយាបថ -ល-។

២-ការអប់រំនេះ ត្រូវឈរលើមូលដ្ឋានគ្រឹះ វិសសរស្ដម្ភទាំងបួន " Les quatre piliers de l'éducation " គឺ :

ក- បង្រៀន-រៀនចំនេះដឹង ( apprendre à connaître)

ខ- បង្រៀន-រៀនធ្វើ (apprendre à faire)

គ- បង្រៀន-រៀន ចេះរស់នៅរួមគ្នា (apprendre à vivre ensemble)

ឃ- បង្រៀន-រៀន អោយមានអាកប្បកិរិយា និងឥរិយាបថល្អ ដើម្បីក្លាយជាមនុស្សពិត (apprendre à être)[១] ។

(១)- ពាក្យបារាំង Apprendre à être បកមិនបានត្រឹមត្រូវតែមួយម៉ាត់បានទេ ។ ពាក្យនេះមានន័យទូលាយវែងឆ្ងាយ ។

ដើម្បីអោយបានយល់ច្បាស់ថែមទៀត ខ្ញុំសូមលើកយកសសរស្តម្ភទាំងបួនមកបកស្រាយជូនដូចតទៅ ។ ខ្ញុំដឹងថា លោកគ្រូ-អ្នកគ្រូ បានយល់ខ្លះរួចហើយនូវន័យនៃពាក្យទាំងបីម៉ាត់គឺ ចំនេះដឹង ចំនេះធ្វើ និងការអប់រំ ដែលមានចែងក្នុងឯកសារជំនួយសំរាប់ពង្រឹកគុណភាពអប់រំនៅបឋមសិក្សា (ផ្នែកទី ៥ កិច្ចតែងការបង្រៀនទំព័រ ១៩៧) ចេញដោយក្រសួង អ.យ.ក កាលពីឆ្នាំ ១៩៩៤ ។

ឥឡូវនេះ យើងនាំគ្នាពិភាក្សាថា តើដោយហេតុអ្វីបានជាគណៈកម្មការអន្តរជាតិផ្តើអោយការសិក្សាអប់រំនៅគ្រប់ប្រទេសលើសកលលោក ឈរលើសសរគ្រឹះទាំងបួន ។ គណៈកម្មការយល់ថា បច្ចុប្បន្នកាលនេះ ដោយមានការរីកចំរើនឥតឈប់ឈរផ្នែកបច្ចេកទេសពត៌មានវិទ្យា ចំនេះដឹងកាន់តែរីកចំរើនខ្លាំងឡើងៗ នាំអោយយកចំនេះដឹង ចំនេះធ្វើ ទៅប្រើក្នុងផ្លូវខុស រឺប្រើសំរាប់តែប្រយោជន៍ផ្ទាល់ខ្លួន មិនបំរើប្រយោជន៍រួម ។

គណៈកម្មការចង់ដាស់ស្មារតីអោយយល់ថា ចំនេះដឹងត្រូវតែស្វែងរកអោយបានច្រើនក៏ពិតមែនហើយ ក៏ប៉ុន្តែត្រូវយកចំនេះដឹង ចំនេះធ្វើនោះ ទៅបំរើសំរាប់អភិវឌ្ឍខ្លួនឯងផង និងសំរាប់សង្គមផង ។ បំនិនប្រសប់ និង សមត្ថភាពជំនាញ គួបផ្សំនិងបញ្ញា បង្កើតបានជាអ្នកបច្ចេកទេសមានកិត្តិយស និងការរាប់អាន លុះត្រាតែអ្នកនោះមានអាកប្បកិរិយា និងឥរិយាបថសមស្របទៅនឹងមជ្ឈដ្ឋានរស់នៅ និងចេះគោរពរាប់អានអ្នកដទៃ ។

លោកគ្រូ-អ្នកគ្រូ មានបទពិសោធន៍ខ្លះហើយអំពីបញ្ហានេះ ។ គ្រូបង្រៀន ដែលមានចំនេះដឹងជ្រៅជ្រះ ចំនេះបង្រៀនពេញលេញ តែខ្វះចរិយាធម៌ គឺមិនមានអាកប្បកិរិយាសមរម្យ មិនអាចទទួលការរាប់អានពីអ្នកស្រុកភូមិបានឡើយ ។ ដូចនេះ តុល្យភាពស្ថិតនៅលើប៉ូលបី ដូចបានលើកមកជូនជ្រាបខាងលើនេះ ។

ជាទីបញ្ចប់ ការរៀបរាប់មកប៉ុននេះ អាចអោយលោកគ្រូ-អ្នកគ្រូបានយល់ថា តំលៃនៃការអប់រំស្ថិតនៅលើការបានរួចផុតភាពអន្ធការ ភាពស្រពិចស្រពិល ភាពច្រងេងច្រងាងច្រឡើសបើស -ល- និងនៅលើការប្រែក្លាយមកជាអ្នកមានចរិយាធម៌ ប្រកបដោយគតិបណ្ឌិត គឺមនុស្សល្អ ពលរដ្ឋល្អ ពលករល្អ ។

ដូចនេះ ការអប់រំត្រូវតែលើកកំពស់នៅគ្រប់ប្រទេស និងគ្រប់ពេលវេលា ព្រោះសង្គមមនុស្សពីជំនាន់មួយទៅជំនាន់មួយ ទាមទារអោយមានមនុស្សប្រព្រឹត្តអំពើល្អ អ្នកត្រឹមត្រូវ គឺមនុស្សសប្បុរស[១] ។ នេះជាគោលដៅនៃការអប់រំ ដែលខ្ញុំបានជូនជ្រាបសព្វគ្រប់អស់ហើយ[២] ។

**យ៉ង់ ឌី**

(១) - សប្បុរស ប្រែថា (គុណនាម) សំដៅសេចក្តីថា "ល្អ ប្រសើរ ត្រឹមត្រូវ"

ឧទាហរណ៍ : មានចិត្តសប្បុរស មានធម៌សប្បុរស មនុស្សសប្បុរស ត្រូវប្រើសំដីសប្បុរសរកគ្នា (វចនានុក្រមខ្មែរ ទំព័រ ១២៦៨) ។

(២) - សូមអានទស្សនាវដ្តីគ្រូបង្រៀន លេខ ១ ទំព័រ ២៩ ។

# វប្បធម៌សន្តិភាព និង អហឹង្សា

(៧ ៣ ៧ ៣)

នៅក្នុងទស្សនាវដ្ដីគ្រូបង្រៀនលេខ ១០ បញ្ញត្តិវប្បធម៌ដែលត្រូវបានពន្យល់ និងអធិប្បាយជូនជ្រាបសព្វគ្រប់អស់ហើយនោះ មានន័យមួយផ្សេងពីវប្បធម៌ដែលខ្ញុំនឹងលើកយកមកអធិប្បាយនៅក្នុងទំព័រនេះ ។

ក្រោយសង្គ្រាមត្រជាក់ត្រូវបានបញ្ចប់ ទស្សនៈវប្បធម៌សន្តិភាពបានចាប់ផ្តើមមានឡើង ដោយមានបំណងប្រាថ្នាប្រែក្លាយវប្បធម៌សង្គ្រាម និងវប្បធម៌ហឹង្សាអោយទៅជាវប្បធម៌សន្តិភាពនិងវប្បធម៌អហឹង្សាវិញ ។

ដូចនេះ វប្បធម៌សន្តិភាព គឺជាកន្សោម (ensemble) នៃតំលៃអាកប្បកិរិយា និងឥរិយាបថដែលបញ្ចេញអោយឃើញតាមកាយ វាចា និងចិត្តក្នុងការគោរពជីវិតរស់នៅ ការគោរពមនុស្ស និងតំលៃមនុស្ស ការគោរពសិទ្ធិមនុស្ស ការបោះបង់ចោលហឹង្សាគ្រប់រូបភាព ហើយយកចិត្តទុកដាក់ទៅលើគោលការណ៍សេរីភាព យុត្តិធម៌ សាមគ្គីធម៌ ការអត់អោន និងការយល់គ្នាទៅវិញ ។

វប្បធម៌សន្តិភាព ផ្ទុយគ្នាស្រឡះនិងវប្បធម៌សង្គ្រាម វប្បធម៌ហឹង្សា ។ សង្គ្រាម និងអំពើហឹង្សាបានបំផ្លាញមនុស្សជាតិយ៉ាងធ្ងន់ធ្ងរ បំផ្លាញអស់នូវអ្វីដែលមនុស្សបានកសាងកន្លងមក ។

សម័យប្រល័យពូជសាសន៍ប៉ុលពតបានត្រូវបញ្ចប់ហើយ ។ មហិច្ឆតាដ៏ខ្មៅនៃអ្នកលោភអំណាចក៏បានស្ងប់ហើយ ។ គំនិតកសាងវប្បធម៌សន្តិភាព និង វប្បធម៌អហឹង្សានៅកម្ពុជា មានជាយូរហែមកហើយតាំងពីកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ ១៩៩១ និងតាមរយៈសន្និសីទជាតិស្តីពីវប្បធម៌សន្តិភាព នៅសាលាភូមិន្ទរដ្ឋបាលកាលពីថ្ងៃទី ១០ និង ១១ ខែ ធ្នូ ឆ្នាំ ១៩៩៩ ។

វាគ្មិនជាតិ និងអន្តរជាតិ បានបញ្ចេញទស្សនៈពីសារៈសំខាន់នៃវប្បធម៌សន្តិភាព និងវប្បធម៌អហឹង្សា ហើយជំរុញអោយប្រែក្លាយទស្សនៈនេះជាសកម្មភាពជាក់ស្តែងក្នុងជីវភាពរាល់ថ្ងៃចាប់ពីឆ្នាំ ២000 ដែលជាឆ្នាំអន្តរជាតិនៃវប្បធម៌សន្តិភាព ។ តើត្រូវធ្វើដូចម្តេចនៅប្រទេសកម្ពុជាយើងនេះ ?

ខ្ញុំយល់ថា សន្និសីទជាតិដែលបានធ្វើកន្លងមកនេះ ជាការស្វែងរកពន្លឺនៃការពិតនៅប្រទេសកម្ពុជា ។ គឺជាជំហានទីមួយដ៏សំខាន់ ព្រោះបើគ្មានទស្សនៈរបស់អស់លោកជាវាគ្មិនជាតិ និងអន្តរជាតិ និងអស់លោក-លោកស្រីដែលបានចូលរួមពិភាក្សាតាមក្រុមនោះទេ ទោះបីជាមានឆន្ទៈដ៏មោះមុតរបស់ពិភពលោកក៏ដោយ ក៏ការបង្កើតវប្បធម៌សន្តិភាពនៅប្រទេសកម្ពុជាមិនអាចសំរេចបានដែរ ។

ជំហានទី ២ ជាដំណាក់កាលដ៏លំបាក ជាភារកិច្ចតំរូវអោយមានការតស៊ូដើម្បីអោយមានការចូលរួមពីព្រះសង្ឃទាំងពីរគណៈ ពីប្រជាជនគ្រប់ស្រទាប់វណ្ណៈ កុមារ យុវវ័យប្រុសស្រី គ្រូបង្រៀន ក្រុមគ្រួសារ សមាគម អង្គការមិនមែនរដ្ឋាភិបាល តំណាងរាស្ត្រ ចៅក្រម អ្នកសារពត៌មាន កងកំលាំងប្រដាប់អាវុធ និងកងកំលាំងសន្តិសុខ ។ ប្រសិនបើមិនអាចសំរេចការចូលរួមពីក្រុមមនុស្សគ្រប់រូបនោះទេ វប្បធម៌សន្តិភាពអាចជាការស្រមើស្រមៃប៉ុណ្ណោះ ហើយមិនមែនជាទិសដៅសំខាន់ដែលនាំអោយប្រទេសកម្ពុជាឆ្លងផុតពីវប្បធម៌សង្គ្រាម និងហឹង្សានោះទេ ។

ជំហានទី ៣ ជាជំហានអនុវត្ត ។ ខ្ញុំសូមលើកឧទាហរណ៍ខាងផ្នែកអប់រំវប្បធម៌សន្តិភាពនៅក្នុងគ្រឹះស្ថានសិក្សាគ្រប់កំរិត ។

នៅឱកាសសន្និសីទជាតិស្តីពីវប្បធម៌សន្តិភាព ឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានធ្វើបទអន្តរាគមន៍មួយ ស្តីពីផែនការជាតិសំរាប់អប់រំវប្បធម៌សន្តិភាពនៅកម្ពុជា ។ ចំណែកឯកឧត្តម ឡាក់ សំអាត អគ្គនាយកយុវជន និងកីឡាស្តីទី បានធ្វើបទអន្តរាគមន៍មួយដែរ ស្តីពីការចូលរួមវិភាគទានរបស់យុវជនក្នុងការបណ្តុះបណ្តាលសន្តិភាព ។

ដូចនេះ យើងឃើញថា ទស្សនៈឯកឧត្តមទាំងពីរចំពោះការអប់រំវប្បធម៌សន្តិភាពនៅកម្ពុជា ជាទស្សនៈភ្លឺថ្លាច្បាស់លាស់ អាចចាត់ទុកបានជាមាគ៌ាអនុវត្តផែនការអប់រំនៅក្នុងគ្រឹះស្ថានសិក្សា ។ក៏ប៉ុន្តែមកទល់ថ្ងៃនេះ ផែនការជាតិដើម្បីអប់រំវប្បធម៌សន្តិភាពនៅក្នុងសាលា មិនទាន់បានចេញដំណើរនៅឡើយទេ ។ **ពីព្រោះអ្វី ?**

ជាទីបញ្ចប់ ខ្ញុំសូមអនុញ្ញាតដកស្រង់ក្នុងសុន្ទរកថា (១) របស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា នូវចំនុចដ៏មានសារៈសំខាន់ដែលលោកគ្រូ-អ្នកគ្រូគួរតែចងចាំ និងឆ្លៀតឱកាសបញ្ច្រាបទៅក្នុងមេរៀនសីលធម៌ពលរដ្ឋ (morale civique) រឺមេរៀនអ្វីទៀតដែលអាចបណ្តុះគំនិតសន្តិភាព និងអប់រំចិត្តគំនិតដើម្បីបំបាត់ហឹង្សា ។

« ខ្ញុំជឿជាក់ថា សន្តិភាពសំរាប់កម្ពុជា មានតំលៃជាងអាយុជីវិតដែលចាំបាច់ត្រូវថែរក្សាដោយប្រុងប្រយ័ត្ន ហើយប្រែក្លាយកម្ពុជា ឱ្យរស់នៅក្នុងវប្បធម៌ដែលខ្លួនចង់បាននេះ គឺវប្បធម៌សន្តិភាពជារៀងរហូត ។ កម្ពុជាចង់ឱ្យឆ្នាំ ២000 របស់ខ្លួន និង សតវត្សថ្មីទី ២១ និង សហស្សវត្សថ្មី ជាឆ្នាំសន្តិភាព សតវត្សសន្តិភាព និង សហស្សវត្សសន្តិភាពរបស់កម្ពុជា និងរបស់ពិភពលោក ។ ពីបំណងនេះកម្ពុជានឹងធ្វើអ្វីៗគ្រប់បែបយ៉ាង ដើម្បីសន្តិភាពពីក្នុងដួងចិត្តរហូតដល់សកម្មភាពប្រចាំថ្ងៃរបស់កម្ពុជា ។ បន្ទាប់ពីសន្តិភាព ដូចលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វីអាណាន់ បានមានប្រសាសន៍ហើយថា បញ្ហាសំខាន់បំផុតដែលនឹងត្រូវប្រឈមមុខនៅក្នុងសហស្សវត្សថ្មីនេះគឺ ការដោះស្រាយឱ្យបាននូវសន្តិសុខរបស់មនុស្ស ... ។ ជាការពិត អវត្តមានរបស់សង្គ្រាម មិនមានន័យគ្រប់គ្រាន់ថា មាន

(១) - សុន្ទរកថាថ្លែងក្នុងឱកាសបើកសន្និសីទជាតិស្តីពីវប្បធម៌សន្តិភាព ។

សន្តិភាពនោះទេ ។ ស្ថេរភាព សន្តិសុខ សណ្តាប់ធ្នាប់ នីតិរដ្ឋ ការគោរពសិទ្ធិមនុស្ស ។ល។ និង ។ល។ គឺជាកត្តាបំពេញអត្ថន័យឱ្យសន្តិភាពដ៏ពេញលេញមួយ បន្ទាប់ពីសង្គ្រាមត្រូវលុបបំបាត់ ។ សន្តិសុខសំរាប់មនុស្ស គឺជាករណីដ៏សំខាន់មួយ ដែលខ្ញុំយល់ថា ចាំបាច់ត្រូវមានវិធានការស្រុះគ្នាលើគ្រប់ផ្នែក រាប់ទាំងផ្នែកតុលាការផងដែរ ទើបយើងអាចជំនះនូវបាតុភាពទាំងអស់នេះបាន ។ យើងនឹងបន្តធ្វើដើម្បីសន្តិសុខរបស់មនុស្សម្នាក់ៗ ហើយមនុស្សម្នាក់ៗប្រាកដជារួមចំណែកកសាងអភិវឌ្ឍន៍ប្រទេសនេះយ៉ាងសកម្មថែមទៀត នៅពេលដែលសន្តិសុខរបស់ខ្លួន គ្មានការគំរាមកំហែងពីពពួកអសកម្ម » ។



« ជនណាដឹងខ្លួនថាល្ងង់ ជននោះហៅថាជាអ្នកប្រាជ្ញ
ជនណាតាំងខ្លួនជាអ្នកប្រាជ្ញ ជននោះហៅថាជាអ្នកល្ងង់ »

( ធម្មបទពាលវគ្គ )

# អត្តសញ្ញាណជាតិ

* * * * * *

ក្រោយពីសៀវភៅអត្តសញ្ញាណប្រទេសកម្ពុជា ត្រូវបានចែកជូនទៅគ្រប់គណៈកម្មាធិការ ស.ប.ស.ខ ខេត្ត-ក្រុងកន្លងមក ខ្ញុំបានទទួលសំនួរពីអ្នកអានខ្លះហើយ ខ្ញុំមានចិត្តរីករាយនឹងឆ្លើយបំភ្លឺចំងល់ពីបញ្ញត្តិអត្តសញ្ញាណ ។ អ្នកខ្លះបានពោលថា « លោកតា ! សូមលោកតាមេត្តាបំភ្លឺ ។ ខ្ញុំមានអាយុ ៣៥ ឆ្នាំហើយ ហើយបានរៀនសូត្រចេះដឹងខ្លះដែរ តែមកទល់ថ្ងៃនេះ ខ្ញុំលឺតែគេនិយាយ និងសរសេរថា អត្តសញ្ញាណជាតិ ចុះហេតុអ្វីបានជាលោកតាដាក់ចំណងជើងសៀវភៅលោកតាថា អត្តសញ្ញាណប្រទេសកម្ពុជាវិញ ? » ។

ចំពោះការបំភ្លឺសំនួរខាងលើនេះ ខ្ញុំសូមបកស្រាយជូនដូចតទៅ :

តើអ្វីទៅដែលហៅថា ជាតិ និង ប្រជាជាតិ ? តាមវចនានុក្រមខ្មែរ ជាតិ ប្រែថា កំនើតមនុស្ស ដែលមានសញ្ជាតិផ្សេងគ្នា : ជាតិខ្មែរ ជាតិចិន -ល- រីឯប្រជាជាតិ ប្រែថា ជាតិនៃមនុស្សដែលមានវង្សត្រកូល និងភាសាជាមួយគ្នា (១) ។

តើពាក្យប្រជាជន ប្រជារាស្ត្រ រឺ រាស្ត្រប្រជា មានន័យដូចម្ដេច ? ពាក្យទាំងពីរនេះសំដៅពួកជនចំនុះ ប្រទេស និងចំនុះដែន (population) ដែលមានន័យប្រហាក់ប្រហែលនឹងជាតិដែរ តែមិនអាចប្រើជំនួសគ្នាបានឡើយ ។

ដើម្បីយល់អោយច្បាស់ពីគំនិតស្ដីពីជាតិ រឺ ប្រជាជាតិ ខ្ញុំសូមជំរាបថា ជាតិនីមួយៗមានចរិតលក្ខណៈ (caractéristique) សំគាល់ប្រាំ (៥) ។ សូមយល់ជាមុនសិនថា ជាតិ ជាក្រុម រឺចំនោមមនុស្ស (un groupe d'individus) រឺជាសហគមន៍ (communauté) ។ ក្រុមមនុស្សនេះ (ឧ. ខ្មែរ) សំដៅយកកំនើតកើតក្នុងដែនកម្ពុជា ជាប់ពូជអំបូរមកជាយូរហើយ ។ បុរសស្ត្រីក្នុងកម្ពុជរដ្ឋ មានលក្ខណៈចរិតដូចតទៅ :

- មានប្រវត្តិជាមួយគ្នា
- រស់នៅលើទឹកដីជាមួយគ្នា
- និយាយភាសាតែមួយដូចគ្នា
- មានវប្បធម៌តែមួយដូចគ្នា (ទំនៀមទំលាប់ សិល្បៈ -ល-)
- មានចិត្តគំនិត អាកប្បកិរិយា ឆន្ទៈរួម -ល-

នេះហើយជាអត្តសញ្ញាណជាតិ ។ ខ្ញុំសូមលើកសំនួរមួយសួរថា ខ្មែរម្នាក់ដែលមានជំនឿជាក់ (Conviction) ថា ខ្លួនជាជាតិខ្មែរនោះ តើមានគំនិតយ៉ាងដូចម្ដេច រឺគិតទៅលើអ្វីបានជាហ៊ានអះអាងថាខ្លួនជាជាតិខ្មែរ ?

ខ្ញុំសូមមិនឆ្លើយទេ ។ ខ្ញុំសូមមិត្តអ្នកអានត្រិះរិះរកចំលើយខ្លួនឯង និងសូមអានអោយបានច្បាស់នូវអារម្ភកថារបស់ខ្ញុំចុះក្នុងសៀវភៅអត្តសញ្ញាណប្រទេសកម្ពុជា ។

(១) - វចនានុក្រមខ្មែរទំព័រ ៦៤៣ ប្រជាជាតិប្រែជាភាសាបារាំងថា Nation. ។

# អាថ៌កំបាំងនៃឈ្មោះភូមិស្រុក

ឈ្មោះស្រុកភូមិដែលដូនតាយើងដាក់អោយ សុទ្ធតែមានស្នាមប្រវត្តិកប់នៅជាប់ជាមួយជានិច្ច ។ ជួនកាលលោកហៅភូមិតាមហេតុប្រវត្តិសាស្ត្រ (ឧ. សៀមរាប ច្រកសៀម) រឺតាមព្រឹត្តិការណ៍ក្នុងជីវភាព (ឧ. ភូមិភ្លើងឆេះរទេះ កំពង់ចំលង) ជួនកាលហៅតាមស្ថានភាពភូមិសាស្ត្រ (ឧ. វាលវែង វាលសោះខ្យល់ ច្រាំងចំរេះ) ជួនកាលហៅតាមជំនឿសាសនា (ឧ. វិហារសួគ៌ ព្រះនិព្វាន) ជួនកាលលោកដាក់ឈ្មោះដូន (ឧ. ដូនទាវ ស្វាយដូនកែវ) ជួនកាលទៀត លោកដាក់ឈ្មោះតា (ឧ. តាសោម តាកែវ តាលោ) ជួនកាលហៅមេ (ឧ. មេមត់ មេ ស ថ្មក) ជួនកាលហៅបា (ឧ. បាភ្នំ បាធាយ បាទី) ។ និយាយដោយខ្លី ឈ្មោះភូមិមួយមានន័យមួយដោយឡែក ដូច្នេះមានបុគ្គលិកលក្ខណៈផ្ទាល់មួយដែលកូនខ្មែរគួរតែដឹង ប្រយោជន៏ស្គាល់ទឹកដីយើងអោយរឹតតែបានច្បាស់ផង ហើយចេះស្រលាញ់រឹតតែបានខ្លាំងទៀតផង ។

ដំបូង គួរយើងពិនិត្យមើល តើស្រុកភូមិដែលតាំងនៅលើទួល ច្រើនមាននាមដូចម្ដេចខ្លះ ។ នេះគឺសេចក្ដីសន្និដ្ឋានរបស់យើង ។

* <u>**ក្រាំង**</u> : ភូមិណាដែលមានពាក្យ "**ក្រាំង**" ច្រើនតែតាំងនៅលើទួលកណ្ដាលវាល ដូចជាក្រាំងម្កាក់ ក្រាំងពង្រ ក្រាំងធ្នង់ នៅក្នុងស្រុកភ្នំពេញ ក្រាំងស្គា ក្រាំងល្វា ស្ទឹងក្រាំង នៅក្នុងខេត្តកំពង់ឆ្នាំង ក្រាំងចេក នៅក្នុងខេត្តកំពង់ស្ពឺ ក្រាំងស្បូវ ក្រាំងលាវ នៅក្នុងខេត្តកំពត ជាដើម ។

* <u>**ខ្នារ**</u> : ពាក្យ "**ខ្នារ**" ក៏មានមុខងារសំគាល់ភូមិស្រុកខ្មែរដែរ ។ ខ្នារ គឺជាទួលខ្ពស់ព័ទ្ធជុំវិញត្រពាំង ។ យើងឃើញថាមាន ខ្នារសណ្ដាយ ក្នុងខេត្តសៀមរាប ខ្នារឆ្មារ ក្នុងខេត្តកំពង់ឆ្នាំង ត្រាំខ្នារ ក្នុងខេត្តតាកែវ ។

* <u>**គោក**</u> : ផុតពីខ្នារយើងមកដល់ "**គោក**" ដែលសំគាល់ទួលកណ្ដាលវាល មិនលិចទឹក ។ នៅភ្នំពេញមានទួលគោក ។ នៅឧត្តរមានជ័យមាន គោកមន គោកខ្ពស់ ។ យើងដាក់គោកបន្ទាយមួយ នៅក្នុងខេត្តកំពង់ឆ្នាំង ដាក់គោកព្នៅ នៅក្នុងខេត្តសៀមរាប គោករមៀត នៅខេត្តបាត់ដំបង គោកព្រិច នៅខេត្តតាកែវ គ្រាន់ជាឧទាហរណ៍ ។ រួមមានខេត្ត "គោកខាន់" ដែលជាខេត្តខ្មែរពីដើម ឋិតនៅជាប់ខាងជើងខេត្តព្រះវិហារ ឯនាយភ្នំដងរែក សព្វថ្ងៃនៅក្នុងដីសៀម ។

* <u>**ដំបូក**</u> : បានដល់ពំនូកដី ដែលកើតមកពីកណ្ដៀរពូន រឺពីធម្មជាតិ ។ ភូមិដែលប្រើពាក្យនេះ មានភូមិដំបូកខ្ពស់ (កំពត) ព្រៃកដំបូក (កំពង់ចាម) -ល- ។

* <u>តាំង</u> : សំគាល់ទួលក្នុងដងព្រៃ ។ ក្នុងខេត្តកំពង់ធំមាន តាំងគោក តាំងក្រសាំង តាំងក្រសៅ ។ កំពង់ចាមមាន តាំងក្រាំង ។ ស្រុកភ្នំពេញមាន តាំងក្រសាំង ។ ឯតាំងលូច និងតាំងយ៉ាង នៅក្នុងខេត្តពោធិសាត់ ។ កំពង់ស្ពឺមាន តាំងក្រូច តាំងសំរោង តាំងសាយ៉ា ។ ឯតាំងផ្លោច និងតាំងក្រសាំងនៅក្នុងខេត្តកំពង់ឆ្នាំង ។

* <u>ទួល</u> : សំដៅទៅទីដីខ្ពស់ជាងផ្ទៃដីធម្មតា ។ ភូមិដែលមានឈ្មោះទួលនេះ មាននៅគ្រប់ខេត្តក្នុងព្រះរាជាណាចក្រ ជាឧទាហរណ៍ខ្លះ ទួលសំរោង ទួលខ្ពស់ ទួលអំពិល ទួលព្រំ ទួលស្វាយ ទួលពះស្រី ទួលគោក ទួលទំពូង ទួលព្រិច ទួលកី ទួលល្បៀប ទួលប្រាសាទ... ។

* <u>ធំនប់</u> : គឺពំនូកដីលើកទប់ផ្លូវទឹក ។ ឈ្មោះភូមិដែល មានប្រើពាក្យទំនប់នេះ ច្រើនឋិតនៅតាមស្រុកសម្បូរណ៍ផ្លូវទឹក ។ ឧទាហរណ៍ : ទំនប់តាសូស (កំពង់ស្ពឺ) ទំនប់ធំ (កណ្ដាល) ។

* <u>ញៀត</u> : គឺទួលទាបសន្ធឹងពីមាត់បឹងរាក់ៗ ទៅទីខាងលើ ឧទាហរណ៍ : ភូមិញៀត វត្តញៀត ។

* <u>រលាំង</u> : បានដល់ទួលដែលឋិតនៅជិតរំលិច ។ ឧទាហរណ៍ : រលាំងគ្រើល រលាំងចក រលាំងឈូក រលាំងអន្លង់ អមលាំង (គឺអមរលាំង) ។ ចម្លែក ភូមិដែលមានពាក្យរលាំងនេះ ច្រើនតែឋិតនៅក្នុងខេត្តកំពង់ស្ពឺ ។

* <u>អង្គ</u> : គឺទួលធំមានស្រះ ។ តួយ៉ាង អង្គតាសោម អង្គស្នួល អង្គតារាជ អង្គប្រី អង្គខ្នារ អង្គមេត្រី អង្គរកា អង្គក្រលាញ់ អង្គសេរី -ល- ។ គួរអោយឆ្ងល់ពេកណាស់ ឈ្មោះស្រុកភូមិដែលមានពាក្យ " អង្គ " ច្រើនតែឋិតនៅក្នុងខេត្តកណ្ដាល តាកែវ កំពង់ស្ពឺ និងកំពត ប៉ុណ្ណោះ ។ ក្រៅពីនេះ ពុំសូវមាន រឹតគ្មានសោះ ។

សូមលោកអ្នកអានអញ្ជើញនឹករកមើល តើឈ្មោះភូមិដែលមានពាក្យដូចយើងអធិប្បាយខាងលើ មានសភាពភូមិសាស្ត្រដូច្នេះមែនរឺពុំមែន ។ តើលោកអ្នកមានស្គាល់ឈ្មោះភូមិណាទៀតទេ ដែលនៅចន្លោះពីឧទាហរណ៍ខាងលើ ? បើមានសូមអញ្ជើញសរសេរមកបន្ថែមក្នុងបញ្ជីយើង ។

( ដកស្រង់ចេញពីទស្សនាវដ្ដីខេមរយានកម្ម ឆ្នាំទី ២ លេខ ៦ ខែមិនា ឆ្នាំ ១៩៦៥ ទំព័រ ៦៦.៦៧.៦៨ ។ )

# អំពីទង់

# ទង់ពុទ្ធសាសនា និង ទង់ជាតិ

តាមធម្មតា ទង់ត្រូវបានគេធ្វើឡើងពីផ្ទាំងសំពត់ រឺចំរៀកសំពត់ ដែលដេរអោយមានសណ្ឋាន និងពណ៌ រឺរូបភាពផ្សេងៗ សំរាប់ប្រើជាកិត្តិយស រឺជានិមិត្តរូបក្នុងប្រទេសនីមួយៗ រឺប្រើសំរាប់សំគាល់តាមសណ្តាប់[១] សាសនានីមួយៗ រឺក៏ប្រើជាគ្រឿងបូជាក៏មាន ។ ទង់ធ្វើដោយក្រដាស រឺពីសំភារៈផ្សេងៗដូចសំពត់ ក៏ហៅថាទង់ដែរ ។ ដោយអនុលោមទៅតាមសណ្ឋាន និងទ្រង់ទ្រាយរបស់វា ទង់ត្រូវបានគេអោយឈ្មោះផ្សេងៗគ្នា ដូចជា : ទង់ជាតិ ទង់ជ័យ ទង់សាសនា ទង់ផ្កាលា ទង់ប្រចាំកង... ។

កំនើតដើមរបស់ទង់ ប្រហែលជាមានប្រភពមកពីសញ្ញាសំគាល់ត្រកូល រឺសំគាល់កុលសម្ព័ន្ធរបស់មនុស្សពីសម័យដើម ។ ការប្រើប្រាស់ទង់ពីដំបូងទី គឺដើម្បីបង្ហាញអត្តសញ្ញាណ ឧត្តមភាព រឺជ័យជំនះរបស់ខ្លួន ប៉ុន្តែ ចាប់តាំងពីបុព្វកាលរៀងមក ទង់ត្រូវបានគេនិយមប្រើទាំងសំរាប់គោលបំនងផ្លូវលោក ទាំងសំរាប់គោលបំនងសាសនា ។

អត្ថបទអក្សរសាស្រ្តពុទ្ធសាសនា មានពាក្យពេចន៍យ៉ាងច្រើនយោងដល់ទង់ ដែលប្រើនៅក្នុងពិធី រឺឱកាសផ្សេងៗ ទាំងសំរាប់ផ្លូវលោក ទាំងសំរាប់ផ្លូវសាសនា ។ មានសេចក្តីយោងច្រើនទៀត បាននិយាយពីការប្រើទង់នៅក្នុងសមរភូមិ ។ គេប្រើទង់ជានិមិត្តសំគាល់រាជរថរបស់ក្សត្រ ពីព្រោះកាលណាគេមើលឃើញពីចំងាយនូវទង់លើចុងចន្ទោលរាជរថ គេអាចសំគាល់បានថា ជាព្រះរាជរថរបស់ស្តេចអង្គណានោះហើយ ។ គេប្រើទង់ មិនមែនគ្រាន់តែជាសញ្ញាសំគាល់កងទ័ព រឺជាសញ្ញាសំគាល់ក្បាលទ័ពប៉ុណ្ណោះទេ ប៉ុន្តែ គេប្រើសំរាប់លើកទឹកចិត្តកងទ័ពផងដែរ ។

## អំពីទង់សាសនា

ទង់ពុទ្ធសាសនា ដែលកំពុងប្រើប្រាស់នៅក្នុងវត្តអារាមទាំងឡាយនៃប្រទេសកម្ពុជា និងនៅក្នុងប្រទេសនានាកាន់ពុទ្ធសាសនាក្នុងពិភពលោក មានកំនើតចេញមកពីប្រទេសស្រីលង្កា ។ នៅទីនោះ ដំបូងឡើយ គេបានច្នៃបង្កើតទង់សាសនាឡើង ទុកជានិមិត្តសញ្ញា រឺជានិមិត្តរូបរបស់ពុទ្ធសាសនិកជនស្រីលង្កា ។ ទង់នោះត្រូវបានបង្ហូតឡើង ដើម្បីប្រើប្រាស់ជាសាធារណៈជាលើកដំបូង និងយ៉ាងឱឡារិកនៅវត្តទីបទុត្តរារាម ស្រុកកោតហេន ដោយព្រះថេរៈមិគេត្ទុវត្តេ គុណានន្ទៈ ក្នុងថ្ងៃពិសាខបូជា ត្រូវនឹងថ្ងៃទី ២៨ ខែមេសា ឆ្នាំ ១៨៨៥ ។ ការបង្កើតទង់នោះឡើង គឺជា

(១) - ទំលាប់ដែលកើតមានដោយបានស្តាប់ បានលឺតៗគ្នា ទំនៀម. បែប. បែបបទ (វចនានុក្រមខ្មែរ) ។

លទ្ធផលប្រយោជន៍មួយ ចេញមកពីចលនាតស៊ូរបស់ពួកអ្នករៀបចំ និងដឹកនាំពុទ្ធសាសនាអោយមានជីវិតរស់ឡើងវិញ នាអំឡុងអឌ្ឍភាគទីពីរ នៃសតវត្សទី ១៩ ក្នុងប្រទេសស្រីលង្កា ។ ការបង្កើតទង់នោះឡើង គឺជាសកម្មភាពប្រកួតប្រជែងមួយ តទល់នឹងសកម្មភាពរាតត្បាតរបស់បេសកជនផ្សព្វផ្សាយសាសនាគ្រិស្តនៃលោកខាងលិច នៅលើកោះស្រីលង្កា ។

គំនិតបង្កើតអោយមានទង់សាសនា គឺដើម្បីបង្ហាញជានិមិត្តរូបនូវឯកភាពរបស់ពុទ្ធសាសនិកជន និងជោគជ័យរបស់ចលនាតស៊ូនៃពួកអ្នករៀបចំដឹកនាំពុទ្ធសាសនា អោយរស់រានឡើងវិញ ។ គំនិតនេះ ត្រូវបានប្រមូលផ្តុំគាំទ្រ និងបង្កបង្កើតឡើង ដោយសមាជិកនៃគណៈកម្មាធិការកូឡុំបូ ដែលបានរៀបចំបុណ្យពិសាខបូជា ក្នុងឆ្នាំ ១៨៨០ ។

លោក វរសេនីយឯក ហេនរី ស្ទីល អូលកូត (Col. Henry Steel Olcott ) បាននិយាយថា : « គឺនៅពេលនោះហើយ ដែលសហសេវិករបស់យើងនៅក្រុងកូឡុំបូ ផ្តើមគំនិតគិតគូរបង្កើតទង់សាសនា ដែលត្រូវប្រជាជាតិកាន់ពុទ្ធសាសនាទាំងអស់អបអរ ទទួលយកទុកជានិមិត្តរូបសាកលនៃជំនឿរបស់គេ ។ បងប្អូនរបស់យើងនៅក្រុងកូឡុំបូ បានរកឃើញគំនិតល្អឯក ដោយបានបញ្ចូលទៅក្នុងទង់សាសនា នូវពណ៌ទាំងប្រាំមួយ (ឆព្វណ្ណរង្សី) ដែលគេធ្លាប់បានឃើញនៅក្នុងរង្វង់រស្មី ផ្សាយចេញពីព្រះកាយព្រះពុទ្ធ » ។

ទង់ពុទ្ធសាសនា កើតបានជារូបរាងប្រាកដឡើង នៅថ្ងៃទី ១៧ មេសា ១៨៨៥ នៅពេលដែលទង់នេះត្រូវបានគេបង្ហាញជាលើកដំបូង នាថ្ងៃនោះ នៅក្នុងសារពត៌មាន " សរសវី សន្ទរេស " ។ ក្នុងការបង្ហាញនេះ គេពុំបានប្រាប់ឈ្មោះអ្នកច្នៃបង្កើតទង់នោះទេ ។ ប៉ុន្តែ គេបាននិយាយយោងដល់អ្នកច្នៃបង្កើតថា មានច្រើនរូប ។ ដូចលោក ក.ហ.ម សុមថិបាល បានធ្វើសេចក្តីសង្កេតថា : " ប្រហែលជាគំនិតគិតធ្វើទង់នេះឡើង ចេញមកតែពីគំនិតរបស់មនុស្សម្នាក់ ហើយពណ៌ទាំងឡាយរបស់ទង់ ចេញមកពីគំនិតមនុស្សផ្សេងៗគ្នា " ។ ពុទ្ធិកសមាគមខាងទេវវិជ្ជានៅក្នុងសៀវភៅឧទ្ទិសចំពោះខួបមួយរយឆ្នាំរបស់ខ្លួន ក្នុងឆ្នាំ ១៩៨០ បានសរសេរសំដែងអភិវន្ទនកិច្ចចំពោះលោក ការ៉ូលីស បូជិថៈ គុណវទេន ដែលជាលេខាធិការនៃគណៈកម្មាធិការក្រុងកូឡុំបូ ថាជាអ្នកច្នៃបង្កើតទង់សាសនា ។ នៅឆ្នាំ ១៩២៨ សារពត៌មាន "សុនទមីនៈ" ក៏បាននិយាយយោងដល់ហេតុការណ៍ដដែលនេះដែរ ប៉ុន្តែគេបានទទួលស្គាល់ថា សមាជិកទាំងឡាយរបស់គណៈកម្មាធិការកូឡុំបូ តែងតាំងឡើងអោយរៀបចំបុណ្យពិសាខបូជា ក្នុងឆ្នាំ ១៨៨៥ ត្រូវបានគេជឿថា បានច្នៃបង្កើតទង់ពុទ្ធសាសនានេះ ។

កាលចេញផ្សាយក្នុងឆ្នាំ ១៨៨៥ នោះ ទង់ពុទ្ធសាសនាមានពណ៌ប្រាំមួយ គឺ ខៀវ (នីលៈ), លឿង (បីតៈ), ក្រហម (លោហិតៈ) ស (ឱទាតៈ) ហង្សបាទ [១] (មញ្ជេដ្ឋៈ) និងពណ៌ចម្រុះទាំងប្រាំ ដែលតាងពណ៌ផ្លេកដូចពន្លឺពេជ្រ (បភាស្វរៈ) ។ ដើមកំណើតពណ៌ទាំងនោះ ត្រូវបានគេយកតាមពណ៌រស្មីទាំងប្រាំមួយ ចាំងចេញពីព្រះកាយព្រះពុទ្ធ

(១) - ពណ៌ក្រហមដូចជាសម្បុរជើងហង្ស (វចនានុក្រមខ្មែរ) ។

បង្កើតជាមណ្ឌលមូល ទំហំប្រមាណ ១,៨០ម ។ យោងតាមសំដីលោកវរសេនីយឯក អូលកូត ពណ៌ដដែលនេះ ត្រូវបានគេប្រើនៅក្នុងទង់របស់លោកសង្ឃទីបេត៏ ដែលមានឈ្មោះថា ដាឡៃឡាម៉ា ។ សណ្ឋានទង់នោះ គឺរាងបួនជ្រុងទ្រវែង ។

ក្នុងពេលដែលពុទ្ធសាសនិកជនស្រីលង្កា បានប្រារព្ធធ្វើបុណ្យពិសាខបូជាជាលើកដំបូង ក្រោមអាណានិគមអង់គ្លេស កាលនោះ លោកវរសេនីយឯក អូលកូត កំពុងឋិតនៅក្នុងប្រទេសឥណ្ឌា ។ លោកបានត្រលប់ទៅកាន់កោះស្រីលង្កាវិញ នៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៨៨៦ ។ លោកបានឃើញទង់ពុទ្ធសាសនាជាលើកដំបូងនៅវត្តទីបទុត្តរារាម, ស្រុកកោតហេន ។ លោកបានកត់ទុកនូវការចាប់អារម្មណ៍ដំបូងរបស់លោកអំពីទង់ពុទ្ធសាសនា ដូចតទៅថា : " នៅពេលគណៈកម្មាធិការកូឡុំបូបានព្រាងទង់, គឺទង់មានសណ្ឋានកន្ទុយស្រួចដូចមេលឹម (Fanion) របស់កប៉ាល់ដែលពុំសមស្របសំរាប់ការដង្ហែរក្បួនបុណ្យ រឺក៏ដោតជាកិត្តិយសដល់ពិធីបុណ្យនៅតាមគេហដ្ឋាន " ។ បន្ទាប់មក លោកបានផ្ដល់យោបល់ថា ទង់គួរតែធ្វើអោយមានរាងរៅធម្មតា និងទំហំប៉ុនទង់ជាតិ ហើយពេលណា គំរូទង់ធ្វើបានហើយ ត្រូវដាក់សុំយោបល់ព្រមអោយប្រើពីព្រះសង្ឃជាន់ខ្ពស់ផង ។ យោងតាមសំនូមពរនេះ ទង់ពុទ្ធសាសនាត្រូវបានកែសំរួលហើយត្រូវបានចេញបង្ហាញខ្លួននៅក្នុងកាសែត " សរសវី កន្ទរេសៈ " នៅថ្ងៃទី ៨ មេសា ១៨៨៦ ។ ទង់ពុទ្ធសាសនាកែសំរួលនេះ ត្រូវបានគេបង្ហូតឡើងត្រដែត នៅថ្ងៃបុណ្យពិសាខបូជា ក្នុងឆ្នាំ ១៨៨៦ នៅក្នុងវត្តអារាមស្ទើរតែទាំងអស់ហើយនិងនៅតាមលំនៅស្ថានជាច្រើន នៅក្នុងប្រទេសស្រីលង្កា ។

ទង់ពុទ្ធសាសនានេះ ក៏បានបញ្ជូលយកទៅប្រើនៅប្រទេសជប៉ុន ក្នុងឆ្នាំ ១៨៨៦ ដោយលោកអនាគារិកធម្មបាល និងលោកវរសេនីយឯក ហេនរី ស្ទីល អូលកូត ហើយក្រោយមក ក៏បាននាំយកមកប្រើនៅប្រទេសភូមា ។ ទង់ពុទ្ធសាសនាត្រូវបានគេទទួលស្គាល់ជាផ្លូវការ ទុកជាទង់របស់ពុទ្ធសាសនិកជនពិភពលោក តាមសេចក្ដីស្នើសុំរបស់សពលោកសាស្ត្រាចារ្យម៉ាឡាឡាសេកេរៈ និងត្រូវបានពុទ្ធិកសមាគមពិភពលោក ក្នុងសម័យប្រជុំមួយ នៅទីក្រុងកូឡុំបូ ក្នុងឆ្នាំ ១៩៥០ អនុម័តទទួលយល់ព្រមប្រើផង ។ ឥឡូវនេះ ទង់ពុទ្ធសាសនាបានទទួលឋានៈជានិមិត្តរូបរបស់ពុទ្ធសាសនាអន្តរជាតិហើយ ។ ប្រទេសកម្ពុជា បានទទួលយកទង់ពុទ្ធសាសនាមកប្រើ ចាប់ពីឆ្នាំ ១៩៥០ រៀងមក ។

កាលនោះ គណៈប្រតិភូខ្មែរមានព្រះមហាសុមេធាធិបតី ជួន ណាត ជោតញ្ញាណោ ព្រះសង្ឃរាជគណៈមហានិកាយជាប្រធាន បាននិមន្តទៅរួមប្រជុំ និងបានមូលមតិបង្កើតទង់ពុទ្ធសាសនាឡើងហៅថា : " ទង់ពុទ្ធិកសមាគមពិភពលោក " ។

**អំពីទង់ជាតិខ្មែរ**

ទង់ជាតិប្រទេសកម្ពុជា មានសណ្ឋានបួនជ្រុងទ្រវែង តាមខ្នាតទង់អន្តរជាតិ ហើយមានពណ៌ខៀវអមពណ៌ក្រហមឆូតបណ្ដោយ ស្របគ្នាលើផ្ទៃទង់ គឺពណ៌ខៀវឆូតលើគែមសងខាង ទំហំនីមួយៗប្រមាណ ១/៤ អមពណ៌ក្រហម

ដែលមានទំហំប្រមាណជិត ២/៤ នៅកណ្ដាល ។ នៅលើផ្ទៃពណ៌ក្រហមនេះ មានរូបប្រាសាទអង្គរវត្តពណ៌ស ឋិតនៅចំកណ្ដាល ។

ក្នុងបណ្ដាពណ៌ទាំងបីនេះ ពណ៌នីមួយៗត្រូវបានគេបកស្រាយ និងផ្ដល់អត្ថន័យនិមិត្តរូបផ្សេងៗ រឺល្បៀងពីគ្នាទៅតាមទស្សនៈយល់ឃើញរៀងៗខ្លួន ។ ប៉ុន្តែជារួម គេនិយមអោយអត្ថន័យដូចតទៅនេះ : ពណ៌ខៀវ តាងសេចក្ដីរុងរឿង ថ្លៃថ្នូរ សុចរិត យុត្តិធម៌ ស្មោះត្រង់របស់ជាតិ រីឯពណ៌ក្រហមតាងសេចក្ដីអង់អាចក្លាហាន ឆន្ទៈមោះមុតរបស់ជាតិ ហ៊ានប្រយុទ្ធ និងធ្វើពលីកម្មគ្រប់យ៉ាង ដើម្បីការពារជាតិ និងមាតុភូមិ ដែលតាងដោយប្រាសាទអង្គរ ពណ៌ស ដ៏ជានិមិត្តរូបនៃសេចក្ដីបរិសុទ្ធ បញ្ញាញាណ ទេពកោសល្យត្រដុងត្រដោម អរិយធម៌ត្រចះត្រចង់ បូរណភាពទឹកដី ឯករាជ្យ អធិបតេយ្យរបស់ជាតិ ។

យើងពុំទាន់បានរកឃើញឯកសារណាបញ្ជាក់ថា ទង់ជាតិរបស់យើងបច្ចុប្បន្ននេះ ចាប់ផ្ដើមកើតមាន និងដាក់អោយប្រើជាផ្លូវការ នៅថ្ងៃ ខែ ឆ្នាំណាពិតប្រាកដទេ ។ យើងគ្រាន់តែបានដឹងខ្លះថា ទង់ជាតិរបស់យើងកើតមាន និងដាក់អោយប្រើនៅពេលមុនអាណានិគមបារាំងដាក់អាណាព្យាបាលលើប្រទេសកម្ពុជា ក្នុងឆ្នាំ ១៨៦៣ ក្នុងរាជ្យព្រះបាទអង្គឌួង ។ ព្រះអង្គបានជ្រើសយករូបប្រាសាទអង្គរវត្ត ដ៏ជាទីសក្ការៈរបស់ខ្មែរ ទុកជាប្រភពបញ្ញាញាណជាតិ និងជានិមិត្តសញ្ញាបោះពុម្ពលើប្រាក់កាក់ និងជានិមិត្តសញ្ញាលើទង់ជាតិ ។

ចំណេរកាលក្រោយមក ទោះបីប្រទេសជាតិមានវិបត្តិ ហើយមេដឹកនាំខ្មែរមាននិន្នាការនយោបាយផ្សេងៗពីគ្នា ឈានទៅដល់ច្នៃបង្កើតទង់ជាតិថ្មី ប្រចាំក្រុមរបស់ខ្លួនក៏ដោយ ក៏មេដឹកនាំនយោបាយទាំងនោះ នៅតែមានគំនិតមួយដូចគ្នា គឺត្រង់យកស្មារតីចងចាំ នៃយុគសម័យអង្គរវត្ត ពោលគឺ យករូបប្រាសាទអង្គរវត្តធ្វើជាគោលបំនងនយោបាយរបស់ខ្លួន ។ ការជ្រើសយកពណ៌ទង់ផ្សេងគ្នា រឺរចនាបថប្រាសាទប្លែកគ្នា ដូចជា ខ្លះយកប្រាសាទកំពូលបី ខ្លះយកប្រាសាទកំពូលប្រាំ ខ្លះទៀតយកប្រាសាទកំពូលបីដែរ តែថែមរូបផ្កាយ ធ្វើជានិមិត្តសញ្ញានៃទង់ជាតិប្រចាំក្រុម រឺរបបគ្រប់គ្រងរបស់ខ្លួនក៏ដោយ ប៉ុន្តែចំនុចរួម គឺរូបប្រាសាទអង្គរវត្តតែមួយ ។ ឯភាពផ្សេងគ្នានៃទង់ជាតិ គឺមានមូលហេតុចេញមកពីបដិបក្ខខាងនយោបាយ ហើយមនោសញ្ចេតនាស្នេហាជាតិ មាតុភូមិ ក៏ផ្អែកលើមូលដ្ឋានបដិបក្ខនេះដែរ ។

ក្រៅពីទង់ជាតិ ដែលជានិមិត្តសញ្ញាសំគាល់ជាតិ គេបានប្រើគ្រឿងលំអខ្លះទៀត ដើម្បីផ្ដល់កិត្តិយស និងឧឡារិកភាពនៅក្នុងព្រះរាជពិធីដង្ហែក្បួនធំៗ ដូចជាចាមរ សែនត្វ័ន បៃមន់ ក្លស់ អភិរមជាដើម ។

សែនត្វ័ន គឺជាឆ្មិតមានសណ្ឋានមូលធ្វើអំពីសំពត់ផ្កាមាស រឺផ្កាប្រាក់ ជាដើម មានដងវែងភ្ជក់ខាងចុង ប្រើសំរាប់ជាគ្រឿងបាំងកំដៅថ្ងៃ មិនអោយចាំងត្រូវ ។

បៃមន់ គឺជាគ្រឿងប្រដាប់មួយប្រភេទ មានសណ្ឋានដូចស្លឹកមន មានដងស្រដៀងនឹងចាមរដែរ. ប៉ុន្តែត្រង់កំពូលមានរាងស្រួច វៀវ ហើយវៀចភ្ជក់ងាកទៅខាងបន្តិច ។

អភិរម រឺអភិរំ គឺជាឆត្រូតមានរំភាយដូចក្ងួស់ សំរាប់ជាគ្រឿងរុងរឿង រឺឯចាមរ គឺជាគ្រឿងមួយប្រភេទ មានសណ្ឋានដូចផ្លិតសំរាប់មន្ត្រីសង្ឃ ទីរាជាគណៈដូច្នោះ ប៉ុន្តែ គ្មានកំពូល និងឆែក១ជុំវិញទេ ហើយមានដងវែង ។ គ្រឿងប្រដាប់ទាំងប៉ុន្មានប្រភេទនេះ ឃើញមានប្រើដើម្បីលើកកិត្តិយស និងសេចក្ដីរុងរឿងនៅក្នុងព្រះរាជពិធីហែក្បួនធំៗ ដូចជាក្នុងព្រះរាជពិធីរាជាភិសេកជាដើម ។

( អត្ថបទដកស្រង់ចេញពីទស្សនាវដ្ដី " កម្ពុជសុរិយា " ឆ្នាំទី ៥០ លេខ ២ គ.ស. ១៩៩៦ និងឆ្នាំទី ៥១ លេខ ៤ គ.ស ១៩៩៧ ។)








# លក្ខណៈពិសេសរបស់វ័យជំទង់

## I- ទស្សនៈទូទៅ :

វ័យជំទង់គិតពីអាយុ ១៤-១៥ ឆ្នាំ ដល់ ១៧-១៨ ឆ្នាំ ។ មានទស្សនៈជាច្រើន បានចាត់ទុកវ័យជំទង់ជាវ័យដែលមានការវិវត្តផ្លូវចិត្ត និងសរីរាង្គកាយ ។ ក្នុងជីវិតមនុស្សទាំងមូល វ័យជំទង់ ជាវ័យដែលត្រូវគេរិះគន់ស្តីបន្ទោសច្រើនជាងគេ ។ ក្នុងក្របខ័ណ្ឌចិត្តវិទ្យា ពពួកចិត្តវិទូសិក្សាស្វែងយល់ទៅលើ :

- ការវិវត្តផ្នែកសរីរាង្គកាយ
- ការវិវត្តផ្នែកចិត្តគំនិត វី អត្តមនសិកា
- ការវិវត្តផ្នែកសកម្មភាពសិក្សា និងសកម្មភាពក្នុងសង្គម
- ការសេពគប់ជាមួយមិត្តភក្តិវ័យស្រករគ្នា
- ការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈជំទង់អោយចុះសំរុងក្នុងសង្គម
- ចំនង់ចំនូលចិត្តចំពោះវិជ្ជាជីវៈក្នុងសង្គម ។

វ័យជំទង់ជាវ័យឆ្លងកាត់ពីកុមារភាព ទៅរកវ័យគ្រប់ការ ។ ពពួកចិត្តវិទូ សិក្សាស្វែងយល់ទៅលើវ័យជំទង់ទៅតាមក្រិត្យក្រមចិត្ត-សង្គម គួបផ្សំជាមួយក្រិត្យក្រមជីវសាស្ត្រ និងឥទ្ធិពលនៃមជ្ឈដ្ឋានសង្គម ។ ក្នុងវ័យនេះ ជំទង់ជួបប្រទះនឹងបញ្ហាច្រើនណាស់ ។ ឪពុកម្តាយជាច្រើនបានពិនិត្យពិច័យឃើញថា កាលណាកូនរបស់គាត់ឈានដល់វ័យនេះ កូនរបស់គាត់ត្រូវឆ្លងកាត់គុណវិបត្តិជាច្រើន ។ ជារឿយៗ ក្មេងជំទង់ច្រើនមិនស្តាប់បង្គាប់មនុស្សចាស់ ដែលមានភាពស្និទ្ធស្នាលជាមួយគេ ។

## II- បន្លាស់ប្ដូរផ្នែកសរីរាង្គកាយ

វ័យជំទង់ជាវ័យឈានទៅរកវ័យគ្រប់ការ និងវ័យមនុស្សចាស់ ។ មុខងារផ្លូវចិត្ត និងសរីរាង្គកាយដ៏ថ្មីស្រឡាងរបស់វ័យជំទង់បានលេចធ្លោឡើង គួរអោយកត់សំគាល់បាន ។ សរីរាង្គកាយលូតលាស់រហ័សណាស់ ។ អាការៈខាងក្រៅខ្លួនគួរអោយកត់សំគាល់បាន មានដូចតទៅ :

- ចាប់ពីអាយុ ១៣-១៤ ឆ្នាំឡើងទៅ គេឃើញមានលេចមុននៅលើផ្ទៃមុខ
- សំលេងចាប់ផ្លាស់ប្ដូរពីសំលេងកុមារ ទៅជាសំលេងគ្រលរបន្តិច
- ចំពោះជំទង់ជាក្មេងស្រី ចាប់ផ្ដើមមានឈាមរដូវពីអាយុ ១២-១៣-១៤ ឆ្នាំទៅ
- កំនត់សំគាល់អោយឃើញនូវភាពគ្រប់ការ ចំពោះជំទង់ប្រុស-ស្រី បែបនេះ បានលេចធ្លោអោយឃើញនូវសភាពផ្លូវចិត្តថ្មីមួយ ។

ជំទង់ដឹងខ្លួនឯងថា គេមិនមែនស្ថិតនៅក្នុងវ័យកុមារទៀតទេ ។ គេកំពុងបោះជំហានទៅរកវ័យមនុស្សចាស់ ។ សញ្ចេតនាថ្មី ក៏ចាប់ផ្ដើមកើតឡើងនៅក្នុងញាណរបស់គេដែរ ។ ជាទូទៅ នៅក្នុងជីវភាពរស់នៅនៃវ័យជំទង់ទាំងពីរប្រភេទ គេពិនិត្យឃើញមានដំនាក់កាលបីយ៉ាង លេចធ្លោឡើង :

- មុនវ័យគ្រប់ការ
- ចូលវ័យគ្រប់ការ
- ការវិវត្តទៅរកការបញ្ចប់វ័យគ្រប់ការ ។

ក៏ប៉ុន្តែក្នុងវ័យនេះ ជំទង់ត្រូវឆ្លងកាត់តែពីរដំនាក់កាលទេ គឺមុនវ័យគ្រប់ការ និងវ័យគ្រប់ការ ។ ក្នុងប្រទេសមូលធន ដែលកំពុងអភិវឌ្ឍខ្លាំង ភាគរយនៃឧក្រិដ្ឋជន កើតចេញពីជួរវ័យជំទង់នេះឯង ដូចជា ក្រុមបនល្បែង ពេស្យាចារ ឃាតកម្ម ចោរកម្ម គ្រឿងញៀន វិវាទកម្ម ... ។ សង្គមបានទំលាក់បទឧក្រិដ្ឋទាំងនេះ ទៅលើក្រុមក្មេងជំទង់ ។ ក្នុងវ័យនេះ ការលូតលាស់នៃសរីរាង្គកាយ និងផ្លូវចិត្ត ជាដំនាក់កាលលោតផ្លោះ ។ ដំនាក់កាលលោតផ្លោះ រឺបន្លាស់ប្ដូរដ៏ឆាប់រហ័សនៃកត្តាទាំងពីរនេះ ជះឥទ្ធិពលយ៉ាងខ្លាំងដល់ការប្រកាន់យកអាកប្បកិរិយាបែបណាមួយនោះរបស់វ័យជំទង់ ។ ការលូតលាស់នៃសរីរាង្គកាយថ្មី និងចិត្តគំនិតថ្មីបែបនេះ ធ្វើអោយជំទង់មានតំរូវការ និងចំនង់ចំនូលចិត្តថ្មី ក្នុងការសេពគប់រកមិត្តភាព និងសកម្មភាពបែបណាមួយនោះ ដែលជូនកាលធ្វើអោយសង្គម និងសាលារៀនជួបវិបត្តិ និងការលំបាក គួរអោយព្រួយបារម្ភ ។ សង្គមអាចជួបវិបត្តិ និងផលវិបាកដ៏ធ្ងន់ធ្ងរ បើរដ្ឋាភិបាល និងបណ្ដាញពតិមាន អប់រំ គ្រួសារ សង្គម សាលារៀន មិនមានវិធានការទប់ស្កាត់ឥទ្ធិពលអាក្រក់ សកម្មភាពមិនល្អរបស់ជំទង់ ។ គឺពេលនេះឯង ដែលទំនៀមទំលាប់ និងវប្បធម៌ជាតិ ចាប់ស្រុតចុះ និងអាប់អោន ។

ក្នុងវ័យនេះ គ្រោងឆ្អឹងលូតលាស់របើសណាស់ ។ ឆ្អឹងដៃ និងឆ្អឹងជើងលូតវែង ធ្វើអោយជំទង់មានរាងកាយស្គមស្តើង ។ កំពស់របស់ជំទង់អាចលូតលាស់បានពី ៥ ទៅ ៦ ស.ម និងទំងន់កើនឡើងពី ២.៥០ គ.ក្រ ទៅ ៤ គ.ក្រ ក្នុងមួយឆ្នាំៗ ។ ដោយសារប្រព័ន្ធឆ្អឹង កំពស់ និងទំងន់រីកលូតលាស់បែបនេះហើយ បានជាជំទង់ចង់ធ្វើអ្វីៗអោយដូចមនុស្សចាស់ ដូចជា គេចង់យូរវ៉ាលីស រឺរបស់ធ្ងន់ៗ អោយដូចមនុស្សពេញវ័យ ។

ក្នុងវ័យនេះ ខួរក្បាលរបស់ជំទង់ចាប់ផ្តើមមានទំងន់ និងមានទំហំ ប្រហែលនឹងខួរក្បាលយុវជន ។ សំបកខួរក្បាល រឺកំរិតខួរ និងទំហំខួរក្បាលរីកចំរើនឆាប់របើសណាស់ ។ មុខងារ និងប្រព័ន្ធសរសៃប្រសាទ កាន់តែជួបលក្ខណៈស្មុគស្មាញ ។ ពពួកអ្នកប្រាជ្ញចិត្តវិទ្យា បានបកស្រាយពន្យល់ពីលក្ខណៈស្មុគស្មាញនេះ ដូចតទៅ ៖

- កង្វះលំនឹងផ្នែកសរីរៈ នាំអោយជំទង់ខ្វះលំនឹងផ្នែកសរីរាង្គទាំងមូល ។ករណីនេះ ជូនកាលបណ្ដាលមកពីជំងឺ រឺអាការរោគពីកំនើត រឺស្មូពូជ រឺបណ្ដាលមកពីរបបអាហារ រឺកង្វះសកម្មភាពកីឡា ។

- ចំពោះក្មេងជំទង់ស្រី ក្នុងអាយុពី ១៤ ទៅ ១៥ ឆ្នាំ ប្រវែងឆ្អឹងហាក់ដូចជាលូតលាស់លឿនជាង ទំហំសាច់ដុំ ធ្វើអោយរាងកាយប្រែប្រួល ជូនកាលមានភាពសង្ហារ គួរជាទីចាប់អារម្មណ៍ដល់អ្នកផង ។

- ក្នុងវ័យនេះ ជំទង់ច្រើនជួបវិបត្តិ និងទទួលរងការស្តីបន្ទោសពីមនុស្សចាស់ ដូចជាករណី ៖ កាន់របស់អ្វីមួយធ្វេសប្រហែសអោយធ្លាក់ពីដៃ រឺជ្រុះបាក់បែក ប្រើប្រាស់របស់ដូចជាយានជំនិះ ធ្វើអោយបាក់បែក រឺទុកដាក់របស់ប្រើប្រាស់មិនត្រូវតាមទំនង ។

- កាលណាចាប់ផ្តើមមានឈាមរដូវ បេះដូងក្មេងជំទង់ស្រី ចាប់ផ្តើមរីកលូតលាស់ចំនួនពីរដងលឿនជាងទំហំសរសៃឈាម ។ ក្នុងករណីនេះ របត់ឈាមក្នុងខ្លួនប្រាណមានដំណើរយឺតបន្តិច ។ ពេលមានឈាមរដូវ បើបេះដូងផ្តល់ឈាមទៅអោយណឺរ៉ូនមិនគ្រប់គ្រាន់ទេ ធ្វើអោយគេរាងឆាប់អស់កំលាំង ។ ដូច្នេះ គេត្រូវធ្វើចលនាសាច់ដុំ និងឆ្អឹងអោយបានញយដង ។

ភាគច្រើននៃក្មេងជំទង់ប្រុស-ស្រី ច្រើនមានប្រតិកម្មអវិជ្ជមានចំពោះបន្លាស់ប្តូររាងកាយរបស់ខ្លួន ពីវ័យកុមារមកវ័យជំទង់ ។ បន្លាស់ប្តូរ និងការលូតលាស់នៃរាងកាយនេះ ត្រូវបានជំទង់ចាប់អារម្មណ៍ និងយល់ដឹងដោយខ្លួនឯង ។ ក្នុងពេលជាមួយគ្នានេះ បញ្ញត្តិផ្ទាល់ខ្លួនដែលទទួលបានពីការសិក្សាក្នុងសាលារៀនតាមរយៈមុខវិជ្ជាសិក្សានានា ក៏ចាប់ផ្តើមអភិវឌ្ឍដែរ ។ គឺក្នុងពេលនេះហើយ ដែលបុគ្គលិកលក្ខណៈរបស់ជំទង់ចាប់ផ្តើមអភិវឌ្ឍ ។ ការអភិវឌ្ឍន៍នៃទំហំរាងកាយ កង្វះបំនិនប្រសប់ ភាពឆ្គាំឆ្គង ភាពមិនរហ័សរហួន រឺភាពប៉ិនប្រសប់ឈ្លាសវៃបែបណានោះ ត្រូវបានទទួលការវាយតំលៃពីមនុស្សចាស់ រឺអ្នកដទៃ ។ ជំទង់ខ្លះមានកំពស់ ទំងន់ រឺពណ៌សម្បុរស្បែក សមាមាត្រសមរម្យទៅនឹងដងខ្លួន ខ្លះទៀតមិនសមាមាត្រទៅនឹងដងខ្លួន ។ ក្មេងជំទង់ស្រី ច្រើនមិនសូវពេញចិត្តនឹងដងខ្លួន ចង្កេះ ដើមទ្រូង ត្រគាក

កំពស់ មាឌ និង ទំងន់ ។ ក្មេងជំទង់ស្រី ចង់បានមុខមាត់មូលស្រស់បស់ និងរាងកាយស្រួចស្រាវ ។ ចំពោះក្មេងជំទង់ប្រុសវិញ គេចង់បានស្មាទូលាយ ត្រគាកចង្អៀត ។ ក្មេងជំទង់ប្រុសច្រើនមានមាឌស្តើងខ្ពស់ ។

ជាទូទៅ ចាប់ពីអាយុ ១៨ ឆ្នាំឡើងទៅ ភាពគ្រប់ការលេចធ្លោអោយឃើញច្បាស់ ។ រាងកាយមានបន្លាស់ប្តូរទៅតាមលក្ខណៈជីវសាស្ត្រ ពោលគឺ របបអាហារ និងរបបប្រព្រឹត្តកីឡា ។ គឺក្នុងពេលនេះហើយ ដែលជំទង់បង្ហាញអោយឃើញនូវសកម្មភាពរបស់គេក្នុងការបន្តពូជបាន ។ ចំពោះក្មេងជំទង់ស្រី ឆាប់មានវ័យចំនាស់ជាងក្មេងជំទង់ប្រុសចំនួនពីរឆ្នាំ ។ កត្តាចិត្តគំនិត និងកត្តាសង្គមចាប់ផ្តើមអភិវឌ្ឍក្នុងពេលដែលជំទង់ចាប់ផ្តើមចូលរៀនថ្នាក់មធ្យមសិក្សា ។ ចូលដល់វ័យយុវជន រឺទីបញ្ចប់នៃវ័យជំទង់ យុវសិស្សមានកំលាំងល្អក្នុងការប្រកួតកីឡា ។ ចាប់ពីអាយុ ១៨ ឆ្នាំឡើងទៅ ជំទង់ឈានដល់ដំនាក់កាលចុងក្រោយនៃការរីកលូតលាស់ផ្នែកជីវសាស្ត្រ ។ ដំនាក់កាលនេះ មានលក្ខណៈជាទូទៅមិនថាជនជាតិណាឡើយ ។ កត្តាលូតលាស់នៃសរីរាង្គកាយនេះ ត្រូវពឹងផ្អែកលើរបបចំណីអាហារ សេដ្ឋកិច្ច គ្រួសារ និងករិតជីវភាពរស់នៅទូទៅក្នុងសង្គម ។ ចូលដល់វ័យយុវជន គិតពីអាយុ ១៨ ឆ្នាំឡើងទៅ យុវជនមានសិទ្ធិផ្នែកនយោបាយ និងទទួលខុសត្រូវចំពោះមុខច្បាប់ ។

## III- ការអភិវឌ្ឍន៍ផ្នែកចិត្តគំនិត រឺ អត្តមនសិកា

វ័យជំទង់ជាវ័យដែលស្ថិតនៅចំនុះឪពុកម្តាយ រឺអ្នកអាណាព្យាបាល ។ ចាប់ពីវ័យ ១៥-១៦ ឆ្នាំឡើងទៅ សមត្ថភាពបញ្ញារបស់ជំទង់ ចាប់ផ្តើមអភិវឌ្ឍស្របពេលដែលជំទង់កំពុងរៀននៅថ្នាក់មធ្យមសិក្សា ។ គេចាប់ផ្តើមជួបប្រទះនឹងសកម្មភាពដ៏ស្មុគស្មាញក្នុងការសិក្សា ។ គេចាប់ផ្តើមប្រកាន់យកជំហរដ៏រឹងមាំក្នុងការសិក្សា ។ គេមានចិត្តប្រកួតប្រជែងក្នុងការដណ្តើមយកស្នាដៃក្នុងការសិក្សា និងការហ្វឹកហ្វឺនបញ្ញា ។ គេត្រូវបំពេញនូវកាតព្វកិច្ចជាច្រើនក្នុងពេលដែលគេរៀននៅថ្នាក់មធ្យមសិក្សា ។ ជំទង់ចាប់ផ្តើមមានគំនិត និងចំនង់ចំនូលចិត្តស្រលាញ់ និងជ្រើសរើសយកមុខវិជ្ជាជីវៈណាមួយក្នុងសង្គម សំរាប់អនាគតរបស់គេ ។ វិចារណញ្ញាណរបស់គេ តំរង់មុខសញ្ញាទៅរកការយល់ស៊ីជំរៅចំពោះខ្លឹមសារវត្ថុ និងបាតុភូតដែលគេត្រូវសិក្សា ។ គេមានគំនិត និងស្មារតីយល់ស៊ីជំរៅ ចំពោះសំរាយបំភ្លឺរបស់គ្រូ ទៅតាមលក្ខណៈវិទ្យាសាស្ត្រ ។ បញ្ញត្តិផ្ទាល់ខ្លួន រឺសតិបញ្ញារបស់គេ ចាប់ផ្តើមអភិវឌ្ឍតាមរយៈ :

- ការចេះបកស្រាយពន្យល់ដ៏លំអិត
- ការចេះប្រៀបធៀប
- ការចេះវិនិច្ឆ័យ
- ការចេះធ្វើសំយោគ
- ការចេះធ្វើអរូបិយកម្ម
- ការធ្វើទូទៅកម្ម

- ការចេះវាយតំលៃ
- ការចេះទិតៀន
- ការចេះទាញសន្និដ្ឋាន
- ការចេះបញ្ចេញមតិយោបល់ ...។

អាកប្បកិរិយារបស់គេចេះតែវិវត្ត ជួនកាលមានស្ថេរភាព ជួនកាលផ្លាស់ប្តូរទៅតាមចំណេះដឹង និង បទពិសោធន៍ដែលគេមាន និងកំពុងទទួលបាន ។ គេផ្តើមចាប់អារម្មណ៍ទៅនឹងមុខរបរផ្សេងៗក្នុងសង្គម ។ គេមានមនោសញ្ចេតនា និងទំនាក់ទំនងស្វែងរកមិត្តភាពជាមួយអ្នកដែលមានវ័យស្រករគ្នា ។ គេកំពុងយកចិត្តទុកដាក់ដល់ទំនាក់ទំនងរបស់គេ ជាមួយនឹងសមូហភាព ចំពោះភារកិច្ចសិក្សា ដើម្បីតំរង់មុខសញ្ញាទៅរកអនាគតដ៏ត្រចះត្រចង់របស់គេ ។ ជំទង់ច្រើនតែមានការជឿងឆ្ងល់ និងចិត្តរំភើបចំពោះការវិវត្តន៍ផ្នែកសរីរៈ និងការផុសចេញនូវគំនិតផ្ទាល់ខ្លួនរបស់គេ ។

ក្នុងវ័យនេះ សកម្មភាពជាគន្លឹះរបស់ក្មេងប្រុសជំទង់ គឺតំរង់មុខសញ្ញាស្វែងយល់ ចង់ឃើញ ចង់ដឹង ពីទំនាក់ទំនងរវាង បុរសនិងបុរស ស្ត្រីនិងស្ត្រី បុរសនិងស្ត្រី ជាពិសេសគឺមនុស្សពេញវ័យក្នុងទំនាក់ទំនងស្នេហា ។ ចិត្តគំនិតរបស់ជំទង់ខុសប្លែកកាលពីនៅវ័យកុមារ ។ កុមារឆាប់ចងមិត្តភាពជាមួយគ្នាណាស់ ទោះណាជាវាមិនទាន់ស្គាល់គ្នាច្បាស់លាស់នៅឡើយក៏ដោយ ។

ឧទាហរណ៍ ៖ កុមារអាយុ ៦-៧ ឆ្នាំ ពេលជួបគ្នា គេចែកនំគ្នាញ៉ាំ រឺលេងកំសាន្តជាមួយគ្នា ។

ចំពោះជំទង់វិញមិនដូច្នោះទេ ។ គេត្រូវប្រើពេលដ៏យូរបង្គួរ មុននឹងចងមិត្តភាពជាមួយអ្នកស្រករវ័យ ។ ជំទង់មានទំនាក់ទំនងគ្នាកាន់តែស្មុគស្មាញ និងសំបូរបែប ។ ជំទង់ច្រើនតែមានប្រតិកម្មផ្លូវចិត្តចាត់ទុកខ្លួនឯងស្មើនឹងមនុស្សចាស់ ។ គេចង់ពង្រីងពង្រីក និងកែទំរង់ទំនាក់ទំនងរបស់គេជាមួយមនុស្សចាស់ ។ កាលពីនៅវ័យកុមារ គេមិនអាចបោះបង់ចោល រឺកែប្រែអាកប្បកិរិយា ចរិត និងសកម្មភាពជាកុមារបានឡើយ ចំពោះមុខមនុស្សចាស់ ។ ជំទង់ចង់បានសមភាពជាមួយមនុស្សចាស់ ។ ជំទង់ខំបញ្ចេញកំលាំង និងធ្វើការអោយមានស្នាដៃដូចមនុស្សចាស់ ។ គេហ៊ានកាច់ដៃល្បងកំលាំងជាមួយមនុស្សពេញវ័យ ។ កាលណាគេធ្វើការជាមួយមនុស្សចាស់ រឺមនុស្សពេញវ័យ ជួនកាលជំទង់ខំធ្វើការងារនោះអោយទាល់តែបានល្អប្រសើរជាងមនុស្សចាស់ ។ ពេលខ្លះជំទង់ចង់អោយមនុស្សចាស់គោរពខ្លួនគេ ។ គឺត្រង់ចំនុចនេះហើយ ដែលជំទង់បង្កអោយមានបដិបក្ខជាមួយមនុស្សចាស់ ។ ជួនកាលជំទង់ត្រូវបានគេគោរពស្មើភាពនឹងមនុស្សចាស់ដែរ ក៏ប៉ុន្តែចាស់ៗភាគច្រើន ច្រើនតែចាត់ទុកជំទង់ថាជាក្មេងៗទៅវិញ ។ ចាស់ៗខ្លះចាត់ទុកថា ទំនាក់ទំនងរវាងជំទង់ និងមនុស្សចាស់ ជាទំនាក់ទំនងធម្មតា ។ ចាស់ៗខ្លះទៀតខ្វះការយល់ដឹងដ៏ជ្រៅជ្រះ និងខ្វះមធ្យោបាយអប់រំជំទង់ជាកូន ចូលចិត្តជេរស្តី ស្តីបន្ទោស រឺវាយកូននៅពេលហូបបាយ នៅចំពោះមុខភ្ញៀវ រឺនៅចំពោះមុខមិត្ត

ភក្តិរបស់កូន នៅពេលដែលជំទង់មានទំនាស់ រឺហ៊ានប្រឆាំងបន្តិចបន្តួចជាមួយមនុស្សចាស់ រឺមនុស្សពេញវ័យ ដូចជាឪពុកម្តាយ រឺបងប្រុសស្រីជាដើម ។ ប្រព័ន្ធផ្សព្វផ្សាយពតិមានគួរអប់រំមាតាបិតាកុំអោយធ្វើបែបនេះ ហើយគួរបង្ហាញ និងណែនាំពីវិធី និងមធ្យោបាយដ៏ល្អសំរាប់អប់រំកូន ចំពោះឪពុកម្តាយបែបនេះឯង ។ គ្រូបង្រៀន និងសាស្ត្រាចារ្យគួរតែយល់ស៊ីជំរៅទៅលើប្រការនេះ ។ ការអប់រំជំទង់បានល្អ វាអាស្រ័យទៅលើទឹកចិត្តអត់ធ្មត់ អហឹង្សា និងការយល់ដឹងរបស់ឪពុកម្តាយ ។

*ឧទាហរណ៍*: ក្មេងប្រុសជំទង់កំពុងលេងអុក ។ ម្តាយកំពុងធ្វើម្ហូបអាហារ ។ ពេលខ្វះទឹកត្រី ម្តាយបានស្រែកហៅកូនអោយទៅទិញទឹកត្រីមួយភ្លែត ព្រោះម្តាយមិនអាចទៅចោលចង្ក្រានបាន ។

កូនដែលជាប់កំពុងលេងអុក ឆ្លើយថា ចាំមួយភ្លែតសិន ។ លុះចាំយូរពេក ម្តាយក៏ស្ទុះទៅច្បាមយកកូនអុកគ្រវែងចោលទៅផ្លូវថ្នល់ ហើយឡូឡាជេរស្តី រអ៊ូរទាំយ៉ាងយូរ ។

គ្រួសារមួយផ្សេងទៀត ជួបប្រទះនឹងករណីប្រហែលគ្នានេះដែរ នៅពេលដែលកូនកំពុងជាប់មាត់ជជែកគ្នាជាមួយមិត្តភក្តិ ។ ម្តាយបានហៅប្រាប់កូនអោយទៅទិញប៊ីចេងអោយម្តាយ ។ ជំទង់បានប្រាប់មិត្តភក្តិរបស់គេអោយចាំមួយភ្លែត រួចវាក៏រត់ទៅទិញប៊ីចេងអោយម្តាយ ។

ដូចនេះ ការអប់រំជំទង់អោយចេះយល់ពីខ្លួនឯង អោយមានទំលាប់ល្អ វាអាស្រ័យទៅលើឪពុកម្តាយ រឺបងប្រុសស្រីក្នុងគ្រួសារ ដែលចេះនិយាយលួងលោមអប់រំណែនាំជំទង់អោយល្អ ជាជាងប្រើអំពើហឹង្សាក្នុងគ្រួសារ ។ ឪពុកម្តាយត្រូវទំលាប់អប់រំកូនអោយល្អ តាំងពីកូននៅតូច រឺនៅវ័យកុមារ ។ ក្មេងជំទង់ខ្លះមានទំលាប់ចេះគួរសម រឺចេះលើកដៃសំពះមនុស្សចាស់ រឺភ្ញៀវតាំងពីនៅកុមារ ។ ជំទង់បែបនេះ ត្រូវអ្នកផងវាយតំលៃថា ជាកូនមានពូជអំបូរល្អ ។

ជំទង់ដែលតាំងខ្លួនឯងថាជាមនុស្សពេញវ័យ គឺជាឆន្ទៈ និងតំរូវការផ្ទាល់ខ្លួនរបស់គេ ។ តំរូវការនេះនឹងក្លាយទៅជាកំលាំងចលករមួយ ដែលអោយជំទង់ហ៊ានធ្វើអ្វីមួយ ដោយអាងលើសមត្ថភាពរបស់គេដូចមនុស្សចាស់ ។

*ឧទាហរណ៍*: ឪពុកម្តាយ រឺបងប្រុសស្រីខ្លះបណ្តោយអោយកូន រឺប្អូនបើករថយន្ត ។ ថ្ងៃមួយមនុស្សពេញវ័យមិននៅផ្ទះ ជំទង់អាចហ៊ានបើករថយន្តទៅឆ្ងាយបាន ។

មនុស្សចាស់ ដូចជាឪពុកម្តាយ មាមីង អ្នកអាណាព្យាបាល និងគ្រូបង្រៀន ត្រូវតាមដាន និងយកចិត្តទុកដាក់ចំពោះឥរិយាបថ និងសកម្មភាពរបស់ជំទង់ ។ គេត្រូវអប់រំ និងពន្យល់ណែនាំជំទង់អោយចេះប្រើប្រាស់កំលាំងចលករ រឺចំនង់ចំនូលចិត្តអោយសមស្របទៅតាមកាលៈទេសៈ បើមិនដូច្នេះទេ កំលាំងចលករអាចជំរុញជំទង់អោយមានគ្រោះថ្នាក់ រឺជាប់បទល្មើសជាមិនខាន ។

*ឧទាហរណ៍* :  មិនត្រូវបណ្តែតបណ្តោយកូនអោយរៀន ចេះផឹកស្រា ស្រាបៀរ ចេះជក់បារី ចេះលេងបៀ ជាមួយឪពុកម្តាយ បណ្តោយអោយកូនអាយុក្រោម ១៨ ឆ្នាំ បើករថយន្ត បណ្តោយអោយកូនមើលខ្សែភាពយន្ត វីដេអូ រឿងឃាតកម្ម រឿងអាសអាភាស ។

ជាគោលការណ៍ មជ្ឈដ្ឋានសង្គម និងស្ថាប័នអប់រំ និងវប្បធម៌ ត្រូវរួមចំណែកជួយបណ្តុះបណ្តាល និងជួយអប់រំបុគ្គលិកលក្ខណៈរបស់ជំទង់អោយចុះសំរុងក្នុងសង្គម តាមរយៈនៃកម្មវិធីផ្សព្វផ្សាយរបស់បណ្តាញពតិមាន ។ ក្នុងវ័យដែលផ្លូវចិត្តជំទង់កំពុងលូតលាស់ មជ្ឈដ្ឋានគ្រួសារ និងសាលារៀន គួរណែនាំជំទង់អោយស្គាល់ស្ថានភាពថ្មី និងមជ្ឈដ្ឋានប្លែកៗជាច្រើន ដើម្បីជួយពង្រីកគំនិតសតិបញ្ញារបស់ជំទង់ ដូចជា :

- ឪពុកម្តាយ ត្រូវនាំកូនចូលពិសាភោជនាហារក្នុងភោជនីយដ្ឋានធំៗ នាំកូនចូលផ្សារធំៗ ដើម្បីទិញឥវ៉ាន់ប្រើប្រាស់ ណែនាំកូនអោយយល់ដឹង និងចេះប្រើប្រាស់ឧបករណ៍នៅក្នុងគ្រួសារមាន យានជំនិះ ទូរទស្សន៍ ម៉ាញ៉េវីដេអូ ... ។

- សាលារៀនត្រូវណែនាំសិស្សជំទង់ទៅមើលកន្លែងកំសាន្ត ឆ្នេរសមុទ្រ រមណីយដ្ឋានទេសចរណ៍ រោងចក្រ មណ្ឌលចិញ្ចឹមសត្វ ចិញ្ចឹមត្រី មណ្ឌលផលិតកម្មសំខាន់ៗ ... ។

អ្នកអាណាព្យាបាល និងអ្នកអប់រំ គប្បីជួយពន្យល់ណែនាំជំទង់អោយចេះស្វែងយល់ពីផលល្អ រឺ ផលអាក្រក់ និងគ្រោះថ្នាក់ដែលបណ្តាលមកពីទង្វើ រឺសកម្មភាពផ្សេងៗ ដូចជា :

- ការមិនគោរពច្បាប់សាធារណៈ
- ការមិនគោរពតាមក្បួនអនាម័យ
- ការប្រើប្រាស់របស់ផ្ទាល់ខ្លួនមិនសមហេតុផល
- ការសេពគប់មិត្តភក្តិ
- ការនិយមវប្បធម៌បរទេស
- ទំនាក់ទំនងស្នេហា និងចំនងមិត្តភាពជាមួយអ្នកស្រុករវ័យ
- ការប្រើអំពើហិង្សា
- ការចេះគោរពសិទ្ធិមនុស្ស
- ការចេះគោរពទំនៀមទំលាប់ប្រពៃណីសាសនា
- អំពើឧក្រិដ្ឋ និង ឃាតកម្ម
- គ្រឿងញៀន បនល្បែង និង បនពេស្យាចារ
- អត្ថប្រយោជន៍នៃការសិក្សា

- លទ្ធផលនៃការធ្វេសប្រហែស និងការមិនយកចិត្តទុកដាក់ក្នុងការសិក្សា ។

មជ្ឈដ្ឋាន និង កត្តានៃឥទ្ធិពលអាក្រក់ងាយអូសទាញជំទង់ណាស់ ហើយវប្បធម៌ជាតិក៏ងាយនឹងស្រុតចុះសាបសូន្យបានដែរ ។ បើវប្បធម៌ជាតិមិនត្រូវបានសង្គមអោយតំលៃ និងលើកតំកើងហើយ មនុស្សមិនអាចរស់នៅមានភាពសុខដុមរមនាឡើយ ។ គេមានការភ័យព្រួយបារម្ភជានិច្ច ចំពោះសុវត្ថិភាពរបស់គេ និងសមាជិកគ្រួសារគេ ។ មនុស្សកើតមកល្អជាទេ តែឥទ្ធិពលអាក្រក់ក្នុងសង្គមទេ ដែលបង្រៀនមនុស្សអោយទៅជាអាក្រក់វិញ ។

មនុស្សចាស់ មិនត្រូវបង្ខិតបង្ខំជំទង់អោយធ្វើការធ្ងន់ធ្ងរអាក្រក់ ដើម្បីទទួលផលកំរៃឡើយ ។ ក៏ប៉ុន្តែ នៅតាមគ្រួសារនីមួយៗ ឪពុកម្ដាយ រឺអាណាព្យាបាលគួរទំលាប់កូនអោយចេះជួយ :

- ការងារផ្ទះ
- ការងារលក់ដូរ
- ការងារស្រែចំការ
- ការងារដទៃទៀតសមស្របទៅតាមសមត្ថភាពរបស់ជំទង់ និងទុកពេលវេលាអោយកូនបានរៀននៅផ្ទះ ។

*ឧទាហរណ៍* : ក្មេងប្រុសជំទង់អាចជួយឃ្វាលគោក្របី ពេលថ្ងៃសំរាករៀន ។
ក្មេងស្រីជំទង់អាចជួយលក់ដូរ ជួយមើលប្អូន ជួយដាំស្ល ជួយកិច្ចការផ្ទះ ។

ទំនាក់ទំនងដ៏ជិតស្និទ្ធរវាងគ្រួសារជំទង់ និងសាលារៀន មានអត្ថន័យសំខាន់ ចំពោះការអប់រំបុគ្គលិកលក្ខណៈរបស់ជំទង់អោយចុះសំរុងក្នុងសង្គម ។ ពេលដឹងថា ជំទង់សេពគប់ក្នុងចំនោមមិត្តភក្ដិអាក្រក់ បានផលកំរៃបំពេញកង្វះខាតបន្តិចបន្តួចក្នុងគ្រួសារ ឪពុកម្ដាយ រឺអាណាព្យាបាលមិនត្រូវបណ្ដែតបណ្ដោយកូនទេ ត្រូវតែសហការជាមួយសាលារៀន ដើម្បីអប់រំណែនាំកូនអោយទាន់ពេលវេលា ។

*ឧទាហរណ៍* : កូនឋិតនៅក្នុងសមាសភាពបនប្រព្រឹត្តល្មើស ។ ពេលបានទទួលពត៌មានពីអ្នកដទៃ ឪពុកម្ដាយមិនត្រូវកាន់ជើងកូន រឺបណ្ដែតបណ្ដោយធ្វើជាមិនអើពើនឹងកូនឡើយ ។

បណ្ឌិត ចាន់ រដ្ឋសថា

# អ្នកសំរបសំរួលប្រកបដោយប្រសិទ្ធភាព

**វត្ថុបំណង** : នៅពេលអានចប់អត្ថបទខាងមុខនេះ នាយកសាលារៀន លោកគ្រូ-អ្នកគ្រូ អាចបកស្រាយពន្យល់បានអំពីតួនាទីរបស់ខ្លួនក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលដោយជោគជ័យ ។

**សំនួរទាក់ទាញការគិត** :

១- តើគ្រូបង្រៀនជាអ្នកសំរបសំរួលដែរឬទេ ? ហេតុអ្វី ?

២- តើអ្នកសំរបសំរួលមានភារកិច្ចធ្វើអ្វីខ្លះ ?

៣- តើត្រូវធ្វើយ៉ាងណា ដើម្បីសំរបសំរួលប្រកបដោយប្រសិទ្ធភាព ?

**សេចក្ដីណែនាំ** :

សូមអ្នកអាន ចំនាយពេល ២០ នាទី ដើម្បីគិត រួចហើយសរសេរចំលើយលើក្រដាសមួយ បណ្ដាគំនិតផ្ទាល់របស់អស់លោក លោកស្រី មុននឹងអានឯកសារនេះ ដើម្បីប្រៀបធៀបគំនិតរបស់អ្នកជាមួយនឹងគំនិតរបស់អ្នកនិពន្ធ ។

បើមានចំងល់ សូមសាកសួរសហការីរបស់អស់លោក លោកស្រី ។ ប្រសិនបើនៅតែមានចំងល់តទៅទៀត សូមសរសេរលិខិតមកការិយាល័យការសមាគមបុគ្គលិកសិក្សាខ្មែរ ដើម្បីធ្វើការបកស្រាយបំភ្លឺ ។

> **សាលារៀនសព្វថ្ងៃនេះ ត្រូវតែបណ្ដុះបណ្ដាលអោយសិស្សចេះគិត**
> **និងរៀនអំពីជាតិរបស់ខ្លួនឯង និង ជាតិនានា ។**
> ( thinking school and learning nation )
>
> ពាក្យស្លោករបស់ប្រទេសសិង្ហបុរី
>
> ( Singapore's saying )

# អ្នកសំរបសំរួលប្រកបដោយប្រសិទ្ធភាព

នៅក្នុងទស្សនាវដ្ដីគ្រូបង្រៀនលេខ ១០ ខ្ញុំបាននិយាយថា ដើម្បីអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល អោយមានប្រសិទ្ធភាព លោកគ្រូ-អ្នកគ្រូ ត្រូវអនុវត្តភារកិច្ចជាអ្នកសំរបសំរួល ។

**តើអ្វីទៅដែលហៅថា " អ្នកសំរបសំរួលប្រកបទៅដោយប្រសិទ្ធភាព "**

តាមប្រសាសន៍របស់លោក Priscilla ការសំរបសំរួល (facilitation) ជាមុខងាររបស់អ្នកដឹកនាំទាំងឡាយដែលមានបំនងធ្វើអោយក្រុមរបស់ខ្លួនមានប្រសិទ្ធភាពក្នុងការរីកចំរើនសន្សឹមៗទៅរកលទ្ធផលល្អ ដើម្បីសំរេចវត្ថុបំនងទាំងឡាយដែលបានគ្រោងទុក (An empowered team to move smoothly and productively towards the attainment of objectives) ។ ហើយតើអ្វីទៅដែលហៅថា ក្រុមអ្នកសំរបសំរួលល្អ កំពុងដឹកនាំនោះ ? តាមលោក Priscilla បានបញ្ជាក់ថា :

ក្រុមនោះជាក្រុមរបស់មនុស្សដែលមានភាពរីកចំរើន ដោយផ្អែកលើមូលដ្ឋានគ្រឹះទាំងឡាយដូចជា : សហការគ្នា ទំនុកចិត្តគ្នា និងទំនាក់ទំនងចែកជូនពត៌មានគ្នាទៅវិញទៅមក ។

អ្នកសំរបសំរួលល្អ ត្រូវតែទទួលខុសត្រូវក្នុងការចាត់តាំងភារកិច្ចរបស់សមាជិកក្នុងក្រុម ពោលគឺអ្នកសំរបសំរួលប្រកបដោយប្រសិទ្ធភាព មានភារកិច្ចធ្វើអោយសកម្មភាពរបស់សមាជិកម្នាក់ៗកើតមានឡើង ហើយបានលទ្ធផលល្អ ។ ដូច្នេះ លទ្ធផលនេះ រួមចំណែកធ្វើអោយអង្គភាពមួយបានសំរេចវត្ថុបំនងទាំងឡាយពោលគឺ សំរេចគោលដៅរបស់អង្គភាពនោះឯង ។ ដើម្បីវាយតំលៃទៅលើលទ្ធផលល្អ គេត្រូវយកកត្តាពីរមកវាយតំលៃ : បរិមាណ និងគុណភាពរបស់សកម្មភាពចូលរួមពីសំណាក់សមាជិកម្នាក់ៗ ។ លោក Priscilla ក៏បានបញ្ជាក់ផងដែរថា " **កំរិតចូលរួមរបស់សមាជិកម្នាក់ៗ អាស្រ័យទៅនឹងបរិយាកាសនៃការទុកចិត្ត** (Trust) " ការផ្ដល់ឱកាសជូន និងកំរិតនៃការជួយអោយការងារកាន់តែមានប្រសិទ្ធភាព ។ ដូច្នេះ លោក Priscilla សន្និដ្ឋានថា ការងារសំរបសំរួលបានចាត់ទុកថាជោគជ័យ កាលណាសមាជិកម្នាក់ៗចូលរួមសកម្មភាពមិនមានសល់ (The involvement and participation of all group members) ។

**តើអ្នកសំរបសំរួលប្រកបដោយប្រសិទ្ធភាព ធ្វើយ៉ាងណាខ្លះ ?**

ជាបឋម អ្នកសំរបសំរួលតែងតែអោយតំលៃនឹងយកមកអនុវត្តនូវសកម្មភាពពីរយ៉ាង :

- សកម្មភាពចូលរួមតាមរយៈសមាជិកម្នាក់ៗស្ដាប់យ៉ាងសកម្ម (active listening) ។

- និងសកម្មភាពចូលរួមដែលសមាជិកប្តូរមតិ បទពិសោធន៍ ចំនេះដឹងជាមួយសមាជិកក្នុងក្រុម (productive communication among participants) ។

និយាយអោយចំ អ្នកសំរបសំរួល ជាអ្នកលើកទឹកចិត្ត (encourage team work) ចំពោះសកម្មភាពដែលអនុវត្តទៅតាមផែនការ ក្រោមការតាមដាន និងសង្កេតដោយអ្នកសំរបសំរួលដោយផ្ទាល់ ។ អ្នកសំរបសំរួលជាអ្នកគ្រប់គ្រង ដឹកនាំ ចាត់តាំងសមាជិកក្នុងក្រុមដើម្បីអោយដឹងថា ការងារក្រុមអាចសំរេចវត្ថុបំនងដោយរបៀបណា ។ ប៉ុន្តែគាត់ធ្វើជាអ្នកអាជ្ញាកណ្តាល មិនប្រាប់អំពីខ្លឹមសារថា តើត្រូវធ្វើយ៉ាងណាជាក់ស្តែងទេ ( they remain neutral regarding content what is achieved ) ។

អ្នកសំរបសំរួលប្រកបដោយប្រសិទ្ធភាពជាអ្នកបង្កើតបរិយាកាសមួយ ដែលលើកទឹកចិត្តអោយសមាជិកក្នុងក្រុមសាកល្បងបញ្ចេញយោបល់ និងបទពិសោធន៍របស់គេ ។

**តើអ្នកសំរបសំរួលដោយប្រសិទ្ធភាពត្រូវមានគុណសម្បត្តិយ៉ាងណាខ្លះ ?**

**អ្នកសំរបសំរួលត្រូវតែមានសមត្ថភាពដូចខាងក្រោម :**

**ក- ផ្នែកចំនេះដឹង :**

អ្នកសំរបសំរួលត្រូវតែទទួលបាននូវការបណ្តុះបណ្តាលអោយចេះធ្វើផែនការ ផ្នែកចាត់ចែងកម្មវិធីការងារក្រុម ជាអ្នកប៉ិនប្រសប់ខាងទំនាក់ទំនង និងចេះធ្វើយ៉ាងណាអោយក្រុមមានប្រសិទ្ធភាព ។

*ឧទាហរណ៍* : ចេះរៀបចំដាក់អ្នកចិត្តស្រាលអោយនៅជាមួយអ្នកចិត្តធ្ងន់ ។ អ្នកពូកែមានយោបល់ច្រើនជាមួយអ្នកមធ្យម ។

**ខ- ផ្នែកឥរិយាបថ :**

- អ្នកសំរបសំរួលមានចិត្តសន្តោសប្រណី និងគោរពសមាជិក ដោយចាត់ទុកថាការខុសឆ្គង គឺជាបទពិសោធន៍សំរាប់កែលំអ ។

- មិនតក់ក្រហល់ចំពោះពេលវេលា ព្រមទាំងគោរពពេលវេលាដោយហ្មត់ចត់ ។

**គ- បំនិន :**

មានភាពប៉ិនប្រសប់ក្នុងការគ្រប់គ្រងក្រុម ព្រមទាំងមានសមត្ថភាពបញ្ចប់ព្រឹត្តិការណ៍ដោយជោគជ័យ ។

*ឧទាហរណ៍ :*

- បញ្ចៀសនូវទំនាស់ រឺបន្សាបនូវស្ថានការណ៍តានតឹងបាន ។

- មិនអោយសមាជិកក្រុមក្លាយទៅជាឈ្លោះនឹងគ្នាបាន ។

- ទប់ស្កាត់អោយបានមិនអោយមានការសើចចំអក និយាយអាក្រក់ពីគ្នាក្នុងពេលបំពេញការងារក្រុម ។

*ឧទាហរណ៍ :* គាត់និយាយថា សូមលោក " ក " កុំប្រកាន់ខឹងអី ខ្ញុំសូមបកស្រាយបញ្ជាក់អោយបាន ច្បាស់ថា តាមការពិតគាត់ចង់និយាយថា យ៉ាងនេះទៅវិញទេ ។ល។

* * * * *

## ចំលើយចំពោះសំនួរក្នុងទស្សនាវដ្ដីគ្រូបង្រៀនលេខ ១០ ទំព័រទី ២៧

**សំនួរ** : តើមួយណាជារូបភាពតំណាងគោលវិធីសិស្សមជ្ឈមណ្ឌល ? ហេតុអ្វី ?

**ចំលើយ** : ក. ជារូបភាពតំណាងគោលវិធីសិស្សមជ្ឈមណ្ឌល ពីព្រោះរូបនេះបកស្រាយអំពីសកម្មភាពទំនាក់ទំនងរវាង សិស្ស និងសិស្ស ក្រោមការសំរបសំរួលរបស់គ្រូបង្រៀន សិស្សប្តូរបទពិសោធន៍គ្នា ចែកចាយគំនិតគ្នា ដើម្បីរកចំនុច ឯកភាព ។ គ្រូផ្តល់ឱកាសអោយសិស្សស្តាប់គ្នាទៅវិញទៅមក ដើម្បីរៀនធ្វើការជាមួយគ្នា ។ សិស្សត្រូវបានលើកទឹក ចិត្តអោយបញ្ចេញមតិរបស់ក្រុមខ្លួនជូនលោកគ្រូ ។

. **រីឯរូប " ខ "** បានបង្ហាញអំពីភាពដាច់គ្នារវាងសិស្សម្នាក់ៗ ។ លោកគ្រូចាត់ទុកថា សិស្សពុំមានសមត្ថភាពទេ ទង្វើ របស់សិស្សមិនល្អទេ ដូច្នេះ កុំអោយខាតពេល លោកគ្រូប្រាប់ការពិត រឺហៅខ្លឹមសារអោយសិស្សកត់តែម្តងទៅ ។ ពោលគឺរូប " ខ " នេះតាងអោយគោលវិធីគ្រូមជ្ឈមណ្ឌល ។

ដោយបណ្ឌិត អ៊ុំ កុច

# ចំនួនប្រជារាស្ត្រតាមខេត្ត-ក្រុង (ឆ្នាំ ១៩៩៨)

តាមលទ្ធផលជំរឿនសរុបចុងក្រោយនូវប្រជារាស្ត្រកម្ពុជា ឆ្នាំ ១៩៩៨ ខ្ញុំបានជូនតារាងសរុបប្រជារាស្ត្រ ក្នុងទស្សនាវដ្ដីលេខ ១០ រួចហើយ ។ ឥឡូវនេះ ខ្ញុំសូមជូនតារាងប្រជារាស្ត្រតាមស្រុកនីមួយៗដែលមានក្នុងខេត្ត ដើម្បីសំរួលការបង្រៀនរបស់លោកគ្រូ-អ្នកគ្រូ ។ សិស្សត្រូវតែដឹងចំនួនប្រជារាស្ត្រនៅក្នុងខេត្ត-ស្រុកខ្លួន ។ គេតែងសួរថា ខេត្តរបស់អ្នកមានប្រជារាស្ត្រប៉ុន្មាននាក់ ? ភ្នំពេញមានប្រជារាស្ត្រប៉ុន្មាននាក់ ? ប្រទេសកម្ពុជាមានប្រជារាស្ត្រប៉ុន្មាននាក់ ? ។ ដូចនេះ ខ្ញុំចាប់ផ្ដើមពី :

## ១- ខេត្តបន្ទាយមានជ័យ :

ស្ថិតនៅភូមិភាគពាយ័ព្យ ក្នុងតំបន់ទន្លេសាប ជាប់នឹងព្រំប្រទល់ប្រទេសថៃ ។

ខេត្តនេះរួមមាន ស្រុកចំនួន៨ ឃុំ៦៣ ភូមិ៦០៤ មានចំនួនប្រជារាស្ត្ររួម ៥៧៧.៧៧២ នាក់ : ប្រុស ២៨៣.៣៥៨ នាក់ ស្រី ២៩៤.៤១៤ នាក់ ។

ចំនួនប្រជារាស្ត្រតាមស្រុកនីមួយៗ ត្រូវបានបែងចែកក្នុងតារាងខាងក្រោម :

| ល.រ | ស្រុក | ចំនួនប្រជារាស្ត្រ | | | ដង់ស៊ីតេប្រជារាស្ត្ររបស់ខេត្ត |
|---|---|---|---|---|---|
| | | សរុប | ប្រុស | ស្រី | |
| ១ | មង្គលបូរី | ១៣៨.១៩០ | ៦៧.៨២១ | ៧០.៣៦៩ | ៨៧នាក់ក្នុងមួយគីឡូម៉ែត្រ |
| ២ | ភ្នំស្រួច | ៤៥.២៥១ | ២១.៧៦៨ | ២៣.៤៨៣ | ការេ ខ្ពស់ជាងដង់ស៊ីតេ |
| ៣ | ព្រះនេត្រព្រះ | ៧០.៦៧៣ | ៣៣.៩៤៤ | ៣៦.៧២៩ | ថ្នាក់ជាតិដែលមានតែ ៦៤ |
| ៤ | អូរជ្រៅ | ១០០.៥៩០ | ៤៩.៩៩០ | ៥០.៦០០ | នាក់/គម$^{២}$ |
| ៥ | សេរីសោភ័ណ (ប្រជុំជន) | ៩៨.៨៤៨ | ៤៨.០៥៦ | ៥០.៧៩២ | |
| ៦ | ថ្មពួក | ៥៣.៥៣៦ | ២៦.៥៩១ | ២៦.៩៤៥ | |
| ៧ | ស្វាយចេក | ៤៧.៩៦០ | ២៣.៤៩១ | ២៤.៤៦៩ | |
| ៨ | ម៉ាឡៃ | ២២.៧២៤ | ១១.៦៩៧ | ១១.០២៧ | |

## ២- ខេត្តបាត់ដំបង

ស្ថិតនៅភាគពាយ័ព្យ ជាប់ព្រំប្រទល់ប្រទេសថៃ ។

ខេត្តនេះរួមមាន ស្រុកចំនួន១២ ឃុំ៨៩ ភូមិ៦១១ មានប្រជារាស្ត្រចំនួន ៧៩៣.១២៩ នាក់ ក្នុងនោះ ប្រុស ៣៨៨.៩៩៩ នាក់ ស្រី ៤០៤.៥៣០ នាក់ ។

ចំនួនប្រជារាស្ត្រតាមស្រុកនីមួយៗ ត្រូវបែងចែកដូចតារាងខាងក្រោម :

| ល.រ | ស្រុក | ចំនួនប្រជារាស្ត្រ | | | ដង់ស៊ីតេប្រជារាស្ត្ររបស់ខេត្ត |
|---|---|---|---|---|---|
| | | សរុប | ប្រុស | ស្រី | |
| ១ | បាណន់ | ៨៥.២៧៧ | ៤១.៥៣០ | ៤៣.៧៤៧ | ៦៨នាក់ ក្នុង ១ គម[២] |
| ២ | បាត់ដំបង | ១១៦.៧៩៣ | ៥៦.៨១៦ | ៥៩.៩៧៧ | |
| ៣ | ស្វាយប៉ោ ( ប្រជុំជន) | ១៣៩.៩៦៤ | ៦៧.៦០៧ | ៧២.៣៥៧ | |
| ៤ | បវេល | ៧៩.០៣៥ | ៣៩.៤៥១ | ៣៩.២៨៤ | |
| ៥ | ឯកភ្នំ | ៦៥.៤០៨ | ៣១.៥៨៤ | ៣៣.៨២៤ | |
| ៦ | មោងឫស្សី | ១៣៤.៣៧៨ | ៦៥.៣៥៦ | ៦៩.០២២ | |
| ៧ | រតនៈមណ្ឌល | ២៣.៩១៩ | ១២.១៥៧ | ១១.៧៦២ | |
| ៨ | សង្កែ | ១០៦.២៦៧ | ៥១.២៦៩ | ៥៤.៩៩៨ | |
| ៩ | សំពៅលូន | ១២.៥១៨ | ៧.២៧៤ | ៥.២៤៤ | |
| ១០ | ភ្នំព្រឹក | ១៥.៣៥៥ | ៧.៨៩៤ | ៧.៤៦១ | |
| ១១ | កំរៀង | ១៤.២១៥ | ៧.៣៦១ | ៦.៨៥៤ | |
| ១២ | សំឡូត | មិនបានជំរឿនព្រោះអសន្តិសុខ | | | |

## ៣- ខេត្តកំពង់ចាម :

ជាខេត្តធំជាងគេបំផុត មានទីតាំងក្នុងតំបន់វាលទំនាប មានព្រំប្រទល់ខាងត្បូងជាប់ប្រទេសវៀត ណាម ។ ប្រជារាស្ត្រសរុបមាន ១.៦០៨.៩១៤ នាក់ ក្នុងនោះប្រុស ៧៧៥.៧៩៦ នាក់ ស្រី ៨៣៣.១១៨ នាក់ ។

ខេត្តនេះមាន ស្រុក១៦ ឃុំ១៧៣ ភូមិ១.៧៤៨ ចំនួនប្រជារាស្ត្រតាមស្រុកនីមួយៗត្រូវបែងចែកដូចតារាង ខាងក្រោម :

| ល.រ | ស្រុក | ចំនួនប្រជាភាស្ត្រ | | | ដង់ស៊ីតេប្រជាភាស្ត្ររបស់ខេត្ត |
|---|---|---|---|---|---|
| | | សរុប | ប្រុស | ស្រី | |
| ១ | បាធាយ | ៩០.៩២០ | ៤៣.៣៨២ | ៤៧.៥៣៨ | ១៦៤ នាក់ ក្នុង ១ គម[២] |
| ២ | ចំការលើ | ១២៥.៨៦២ | ៦១.៥០០ | ៦៤.៣៦២ | |
| ៣ | ជើងព្រៃ | ៧៤.៨៥៩ | ៣៥.១៨១ | ៣៩.៦៧៨ | |
| ៤ | តំបែរ | ៥១.៦៥០ | ២៥.២៣៣ | ២៦.៤១៧ | |
| ៥ | កំពង់ចាម (ទីប្រជុំជន) | ៤៥.៣៥៤ | ២២.០៨៩ | ២៣.២៦៥ | |
| ៦ | កំពង់សៀម | ៩៩.០៥៦ | ៤៧.៤៧២ | ៥១.៥៨៧ | |
| ៧ | កងមាស | ៩១.២១២ | ៤៣.៥០២ | ៤៧.៧១០ | |
| ៨ | កោះសូទិន | ៧០.៦៧២ | ៣៣.៣៩២ | ៣៧.២៨០ | |
| ៩ | ក្រូចឆ្មារ | ៩៩.៦៩៥ | ៤៨.១១១ | ៥១.៥៨៤ | |
| ១០ | មេមត់ | ១១១.២៩៦ | ៥៤.០៧៨ | ៥៧.២១៨ | |
| ១១ | អូរាំងឪ | ៨២.៨០៦ | ៣៩.៣២៧ | ៤៣.៤៧៩ | |
| ១២ | ពញាក្រែក | ១២៣.៨៧៩ | ៥៩.៧៩៧ | ៦៤.០៨២ | |
| ១៣ | ព្រៃឈរ | ១២៧.៦៨៣ | ៦១.៦៣៥ | ៦៦.០៤៨ | |
| ១៤ | ស្រីសន្ធរ | ៩១.៧៦៥ | ៤៣.៩៦៩ | ៤៧.៧៩៦ | |
| ១៥ | ស្ទឹងត្រង់ | ១០៧.៤២៥ | ៥២.៨២២ | ៥៤.៦០៣ | |
| ១៦ | ត្បូងឃ្មុំ | ២១៤.៧៨០ | ១០៤.៣០៦ | ១១០.៤៧៤ | |

* នឹងមានផ្សាយបន្តចំពោះខេត្ត-ក្រុងដទៃទៀត ។

« អ្នកអប់រំត្រូវប្រយ័ត្នប្រយែងរឺកពា សំដីសំដៅអោយណាស់
ព្រោះដ្បិតពាក្យសំដី និងរឹកពារបស់គ្រូនឹងជ្រាបចូលទៅដក់
ក្នុងក្បាលសិស្ស ដោយមិនដឹងខ្លួន ៗ »

# ចំនោទទី ២០

- កម្រិតថ្នាក់ : ទី ៣ ទី ៤ ទី ៥
- ចំនេះដឹងគណិតវិទ្យាចាំបាច់ : ប្រៀបធៀបចំនួន ប្រមាណវិធី បូក ដក រហូតដល់ ២០០០ ។
- សមត្ថភាពដែលត្រូវអភិវឌ្ឍ : ជ្រើសរើសបំរាប់ និងបង្កើតទំនាក់ទំនងរវាងបំរាប់ ។

**ចំនោទ :**

ចូរពិនិត្យព្រឹត្តិបត្រពតិមានរបស់អ្នកនិពន្ធខ្មែរទាំង ៣ រូប :

| |
|---|
| លោក **គុយ ឡុត** |
| កើតនៅឆ្នាំ 1940 បានសរសេររឿង « អ្នកតាឃ្លាំងមឿង » នៅឆ្នាំ 1969 |
| បានទទួលមរណភាពក្នុងឆ្នាំ 1975 |

| |
|---|
| លោក **រិវង្ស គោវិទ** |
| កើតនៅឆ្នាំ 1939 បានសរសេររឿង « សែនវិយោគ » នៅឆ្នាំ 1959 |
| បានទទួលមរណភាពក្នុងឆ្នាំ 1975 |

| |
|---|
| លោក **គឹម សែត** |
| កើតនៅឆ្នាំ 1930 បានសរសេររឿង « ជើងមេឃថ្មី » នៅឆ្នាំ 1959 |
| បានទទួលមរណភាពក្នុងឆ្នាំ 1975 |

១- តើលោក គឹម សែត អាចអានរឿង « អ្នកតាឃ្លាំងមឿង » បានដែរឬទេ ?

២- តើលោក គឹម សែត មានអាយុប៉ុន្មាន ពេលគាត់និពន្ធរឿង « ជើងមេឃថ្មី » ?

៣- តើអ្នកនិពន្ធណាដែលមានអាយុបានច្រើនជាងគេ ? ពេលទទួលមរណភាពគាត់មានអាយុប៉ុន្មាន ?

៤- តើអ្នកនិពន្ធទាំងបីរូបនេះ អាចជួបគ្នាបានដែរឬទេ ?

## លំនាំនៃការបង្រៀន

១- ចំលងចំនោទដាក់លើក្ដារខៀន ។

២- អោយសិស្សអានចំនោទដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេបានអាន និងពីអ្វីដែលគេត្រូវធ្វើដោយសំដីផ្ទាល់របស់គេ (យ៉ាងតិចបី រឺបួននាក់) ប៉ុន្ដែ មិនមែនអោយអានចំនោទទាំងមូលឡើងវិញទេ ។

៤- ទុកពេលគ្រប់គ្រាន់អោយសិស្សដោះស្រាយចំនោទជាបុគ្គល ។ បើសិស្សមិនអាចដោះស្រាយបានទេ គ្រូគួរអោយសិស្សអានចំនោទម្ដងទៀតដោយយកចិត្តទុកដាក់ រួចសួរសិស្សខ្លះដើម្បីផ្ទៀងផ្ទាត់ថា តើសិស្សយល់អត្ថន័យរបស់ចំនោទហើយរឺនៅ ?

*ឧទាហរណ៍* :

- តើចំនោទនោះគេនិយាយអំពីអ្វី ?
- តើគេនិយាយអ្វីខ្លះអំពីតួអង្គទាំងនោះ ? (តើគេអាចស្រង់ពតិមានអ្វីខ្លះ អំពីពួកគាត់ ?)
- តើអ្នកទាំងនោះកើតនៅឆ្នាំដូចគ្នាដែររឺទេ ?

<u>**សូមប្រយ័ត្ន**</u> ! សំនួរទាំងនេះ គ្រាន់តែជួយអោយសិស្សយល់អត្ថន័យរបស់ចំនោទប៉ុណ្ណោះទេ មិនមែនជាសំនួរដែលចង្អុលបង្ហាញសិស្សអោយដោះស្រាយចំនោទនោះទេ ។

៥- ទុកពេលអោយសិស្សដោះស្រាយចំនោទម្ដងទៀត ។

៦- ធ្វើកំនែរួមនៅលើក្ដារខៀន ដោយអោយសិស្ស 2 រឺ 3 នាក់ ឡើងមកបង្ហាញចំលើយ ព្រមទាំងអោយរកអំនះអំនាងមកបញ្ជាក់ចំពោះចំលើយរបស់គេផង ។

## ចំលើយ :

១- លោក គីម សែត អាចអានរឿង « អ្នកតាឃ្លាំងមឿង » បាន ពីព្រោះនៅឆ្នាំ 1969 ដែលជាកាល បរិច្ឆេទនៃការសរសេរសៀវភៅ គាត់មានអាយុច្រើនហើយ ។គាត់មិនទាន់ទទួលមរណភាពនៅឡើយ ។

<u>សំគាល់</u> : បើសិស្សអាចបញ្ជាក់បានថា គាត់មានអាយុ 39 ឆ្នាំ ជាការប្រសើរណាស់ ប៉ុន្ដែ មិនចាំបាច់ក៏បាន ពិសេសចំពោះថ្នាក់ទី 3 ។

២- ពេលលោក គីម សែត សរសេររឿង « ជើងមេឃថ្មី » គាត់មានអាយុ 29 ឆ្នាំ ។

គេអាចមានអំនះអំនាង 2 :

1959 - 1930 = 29

- ដើម្បីឡើងពី 1930 ទៅដល់ 1959 គេត្រូវបន្ថែម 29

៣- ចំពោះចំលើយទី 3 គេអាចឆ្លើយបានច្រើនបែប :

ក) - ពួកគាត់ទាំងអស់សុទ្ធតែទទួលមរណភាពនៅឆ្នាំជាមួយគ្នា ដូចនេះ អ្នកដែលកើតមុនគេ គឺមានអាយុច្រើនជាងគេ ។ ដូចនេះ គឺលោក គីម សែត ដែលកើតនៅឆ្នាំ 1930 :

1975 - 1930 = 45

រឺ ដើម្បីឡើងពី 1930 ទៅដល់ 1975 គេត្រូវបន្ថែម 45 គាត់មានអាយុ 45 ឆ្នាំ ។

ខ)- 1975 - 1940 = 35
1975 - 1939 = 36
1975 - 1930 = 45

គឺអ្នកនិពន្ធដែលបានកើតនៅឆ្នាំ 1930 មានអាយុច្រើនជាងគេ ពីព្រោះគាត់ស្លាប់នៅក្នុងអាយុ 45 ឆ្នាំ ។ អ្នកផ្សេងមានអាយុតិចជាងគាត់ ។

<u>សំគាល់</u> : ចំលើយទាំងពីរនេះ ត្រូវដូចគ្នា ។ គ្រូមិនចាំបាច់បង្ខំសិស្សអោយធ្វើប្រមាណវិធីទាំង 3 ទេ ប្រការសំខាន់គឺត្រូវចេះរកអំនះអំនាងដើម្បីបញ្ជាក់ចំពោះចំលើយណាមួយ ។

៤-អ្នកទាំងនោះ អាចជួបគ្នាបានចាប់ពីឆ្នាំ 1940 ឡើងទៅ រហូតដល់ឆ្នាំ 1975 ។

---

# ចំណោទទី ២២

- កំរិតថ្នាក់ : ទី ៣ ទី ៤
- ចំនេះដឹងគណិតវិទ្យាចាំបាច់ : ប្រមាណវិធីបូកពីរ រឺបីខ្ទង់ រហូតដល់ ១០០
- សមត្ថភាពដែលត្រូវអភិវឌ្ឍ : ជ្រើសរើស និងរៀបចំពត៌មាន ។

**ចំនោទ :**

យើងនាំគ្នាលេងល្បែងដាក់ដុំគ្រួសចូលក្នុងរង្វង់ទាំងឡាយ ដែលមានលេខដូចខាងក្រោម :

(20) (10) (30) (15) (25) (50) (40) (10) (60)

ចូរគូររង្វង់ដែលមានលេខទាំងនោះដាក់លើក្រដាសព្រាងរបស់អ្នក ។

យើងអាចលេងបានពីរដង :

* លើកទី 1 យើងដាក់ដុំគ្រួស 3 អោយចូលក្នុងរង្វង់ 3 ដើម្បីអោយបានផលបូកចំនួនក្នុងរង្វង់ទាំង 3 នោះស្មើនឹង 60 ។

* លើកទី ២ យើងដាក់ដុំគ្រួស 2 ទៀត ចូលក្នុងរង្វង់ពីរផ្សេងទៀត ដើម្បីអោយបានផលបូកលើកទី 2 ស្មើនឹង 75 ។

ត្រូវប្រយ័ត្ន ! យើងអាចដាក់ដុំគ្រួសក្នុងរង្វង់នីមួយៗបានតែម្ដងទេ ។

**លំនាំនៃការបង្រៀន**

១- ចំលងចំនោទទាំងមូលដាក់លើក្ដារខៀន ដោយទុកមួយផ្នែកសំរាប់ធ្វើកំនែ ។

២- អោយសិស្សអានចំនោទដោយស្ងៀមស្ងាត់ និងដោយយកចិត្តទុកដាក់ ។

៣- អោយសិស្សដោះស្រាយចំនោទលើក្រដាសព្រាង ។

៤- អោយសិស្សគូររង្វង់លើក្រដាសព្រាង តាមគំនូរដែលមាននៅលើក្ដារខៀន ។

៥- អោយសិស្សអានសំនួរម្ដងទៀត ។

៦- សួរសិស្សថា : ចំនោទនេះ គេអោយប្អូនធ្វើអ្វីខ្លះ ? អោយសិស្សប្រាប់មកវិញដោយសំដីផ្ទាល់របស់គេ អោយបានច្រើននាក់ ( អោយសិស្សឆ្លើយតាមការយល់ឃើញរបស់គេ មិនមែនអោយអានចំនោទឡើងវិញទេ ) ។

៧- ទុកពេលគ្រប់គ្រាន់អោយសិស្សធ្វើចំនោទជាបុគ្គល រឺជាដៃគូ ( 2 នាក់ ) ។

៨- ធ្វើកំនែរួមនៅលើក្ដារខៀន :

- អោយសិស្សប្រាប់ចំលើយផ្សេងៗរបស់សំនួរទី 1
- ផ្ទៀងផ្ទាត់អោយដឹងថា សុទ្ធតែជាចំលើយត្រឹមត្រូវ
- ចំលងចំលើយនៅលើក្ដារខៀនជាបីជួរ :

ក) - 20 + 10 + 30

ខ) - 20 + 25 + 15

គ) - 40 + 10 + 10

- សួរសិស្សដែលបានរកឃើញចំលើយដូចចំលើយ -ក- (ជូរទី ១) អោយប្រាប់ចំលើយទី ២ របស់ខ្លួន :

25 + 50 រឺ 60 + 15

* ចំពោះចំលើយនីមួយៗដែលសិស្សបានផ្ដល់មកអោយគ្រូ គ្រូត្រូវផ្ទៀងផ្ទាត់ថា ត្រឹមត្រូវហើយរឺនៅ ? (ផលបូកនៃពីររង្វង់នោះស្មើ 75 ហើយចំនួនដែលប្រើលើកនេះ សុទ្ធតែជាចំនួនដែលមិនទាន់បានប៉ះពាល់នៅលើកទី ១ ) ។

- សូមធ្វើដូចគ្នាចំពោះចំលើយ -ខ- (ជូរទី 2) រួចហើយទើបបន្តទៅចំលើយ -គ- (ជូរទី 3) ទៀត ។ គ្រូត្រូវយកចិត្តទុកដាក់ធ្វើយ៉ាងណាអោយសិស្សទាំងអស់បានចូលរួមធ្វើកំនែ ។

* ចំពោះចំលើយ ខ : 20 + 25 + 15 គឺគេមិនអាចឈានទៅរកចំលើយនៅលើកទី 2 បានទេ ពីព្រោះគេបានប្រើចំនួន 25 និង 15 រួចហើយ ។ ប្រការនេះ មិនមែនគ្រូជាអ្នកពន្យល់សិស្សទេ ប៉ុន្តែ គ្រូត្រូវអោយសិស្សឡើងមកបង្ហាញហេតុផលដល់ថ្នាក់រៀនទាំងមូល ចំនួន 25 និង 15 បានប្រើរួចហើយ ។

<u>**ចំលើយ**</u> :

| | | |
|---|---|---|
| 20 + 10 + 30 | និង | 25 + 50 |
| 20 + 10 + 30 | និង | 60 + 15 |
| 40 + 10 + 10 | និង | 25 + 50 |
| 40 + 10 + 10 | និង | 60 + 15 |





# សំណួរត្រិះរិះ

អត្ថបទដែលខ្ញុំចំលងជូនដូចខាងក្រោមនេះ ជាអត្ថបទផ្សាយចេញពីក្រសួង អ.យ.ក ហើយសុទ្ធតែមានចំនងជើង ។ ប៉ុន្តែ ចំនងជើងនោះ មិនស្របគ្នា ខ្លះសរសេរគោលដៅអប់រំជាគោលការណ៍អប់រំជាតិ ។ គោលការណ៍អប់រំជាគោលនយោបាយអប់រំ ។ម្យ៉ាងទៀត វត្ថុបំនងអប់រំ ជាគោលដៅអប់រំទៅវិញ ។

ចំពោះអត្ថបទទាំងនេះ ខ្ញុំកាត់ចំនងជើងចេញអស់ហើយ ។ ខ្ញុំសូមលោកគ្រូ-អ្នកគ្រូ ឆ្លៀតអាន ឆ្លៀតគិតជញ្ជឹង ហើយដាក់ចំនងជើងមកវិញ ស្របតាមចំនេះដឹងរបស់អស់លោក និងស្របតាមសំនេរនីមួយៗដូចតទៅនេះ ។

<u>**សំនេរទី ១**</u> :

ប្រទេសនីមួយៗ សុទ្ធតែមានការអប់រំសំរាប់ជាតិសាសន៍របស់ខ្លួន និងសុទ្ធតែមានគោលការណ៍ច្បាស់លាស់ ។ សំរាប់ប្រទេសកម្ពុជាយើង គោលដៅអប់រំ គឺកសាងមនុស្សពេញលេញ រីកចំរើនលូតលាស់លើគ្រប់ផ្នែកប្រកបដោយតុល្យភាពព្រមៗគ្នា រវាងប្រាជ្ញា ស្មារតី សញ្ចេតនា និងរូបរាងកាយ ។

ដើម្បីសំរេចគោលដៅនេះ សាលារៀន និងគ្រឹះស្ថានសិក្សាទាំងអស់ មានភារកិច្ចបណ្ដុះបណ្ដាលជំនាន់យុវវ័យ អោយទៅជាពលរដ្ឋល្អ និងពលករល្អ ដែលមានចំនេះដឹង បំនិនប្រសប់ សីលធម៌ ស្មារតីស្នេហាជាតិ និងមានសមត្ថភាពកសាង សុខមាលភាព គ្រួសារ និង សង្គម ។

<u>**សំនេរទី ២**</u> :

១-សកលកម្មអប់រំចំនេះទូទៅមូលដ្ឋាន ៩ឆ្នាំ អភិវឌ្ឍន៍អក្ខរកម្ម វិជ្ជាជីវៈ និងបំពេញវិជ្ជាផ្សារភ្ជាប់ទៅនឹងជីវភាពជាក់ស្ដែង ។

២- ទំនើបកម្មអប់រំ និងកែលំអគុណភាពអប់រំ តាមរយៈការកែទំរង់លើគ្រប់ផ្នែក ពិសេសកម្មវិធីសិក្សា និងសៀវភៅសិក្សា ការកែលំអការគ្រប់គ្រង អធិការកិច្ច និងការកសាងមូលដ្ឋានសំភារៈបរិក្ខារ ។

៣- ការផ្សារភ្ជាប់ការបណ្តុះបណ្តាល ទៅនឹងតំរូវការជាក់ស្តែងនៃសេដ្ឋកិច្ចទីផ្សារ ដើម្បីលើកកំពស់សមត្ថភាពរបស់ជំនាន់យុវវ័យ អោយអាចយកចំនេះដឹង និងបំនិនប្រសប់របស់ខ្លួនទៅប្រើប្រាស់បានក្នុងជីវភាពគ្រួសារ និងជីវភាពសង្គម ។

៤- ការស្តារ និងអភិវឌ្ឍន៍ការងារ យុវជន និង កីឡា ទាំងក្នុងក្របខ័ណ្ឌសាលារៀន និងក្រៅសាលារៀន ដើម្បីប្រមូលកម្លាំងយុវជនទាំងអស់ អោយរួមគ្នាធ្វើសកម្មភាព យុវជន និង កីឡា សំរាប់បុព្វហេតុជាតិ ។

<u>**សំនេរទី ៣ :**</u>

*ការអប់រំជាក់ស្តែង* : គោលការណ៍សំខាន់ៗមួយចំនួនដូចខាងក្រោម អាចជាជំនួយស្មារតីដល់ការអនុវត្ត

១- គោលការណ៍ផ្សារភ្ជាប់ការអប់រំ ទៅនឹងគោលមាគ៌ានយោបាយដឹកនាំរបស់ប្រទេស

២- គោលការណ៍ផ្សារភ្ជាប់ការអប់រំ ទៅនឹងជីវភាពរស់នៅរបស់គ្រួសារ និងសង្គម

៣- គោលការណ៍ផ្សារភ្ជាប់ការអប់រំ ទៅនឹងការងារពលកម្ម

៤- គោលការណ៍ឯកភាពរវាងការអប់រំ មនសិកា និងការបណ្តុះបណ្តាលចំនេះដឹង និងសកម្មភាព

៥- គោលការណ៍អប់រំ ដោយគោរពបុគ្គលិកលក្ខណៈរបស់សិស្ស

៦- គោលការណ៍អប់រំ ក្នុងសមូហភាព និងឆ្លងតាមសមូហភាព

៧- គោលការណ៍អប់រំ អោយមានលក្ខណៈជាប្រព័ន្ធ និងលក្ខណៈបន្ត ។

<u>**សំនេរទី ៤ :**</u>

គឺជាវត្ថុបំនងនៃការរៀន មិនមែនជាវត្ថុបំនងនៃការបង្រៀននោះទេ ពោលគឺអ្វីៗ ដែលជាសមត្ថភាពរបស់សិស្សក្រោយពេលសិក្សា : សិស្សមានសមត្ថភាពអាចធ្វើបាន ប្រតិបត្តិបាន បន្ទាប់ពីបានរៀនរួចហើយ ។ ប៉ុន្តែចង់អោយសិស្សមានសមត្ថភាពយ៉ាងណាៗនោះ គឺត្រូវអាស្រ័យជាចាំបាច់ ទៅលើសមត្ថភាពរបស់គ្រូបង្រៀន ព្រមទាំងកត្តាពាក់ព័ន្ធផ្សេងៗទៀត ។

<u>**សំនេរទី ៥ :**</u>

ប្រព័ន្ធអប់រំកម្ពុជា មានទិសដៅកសាងមនុស្សពេញលេញ ល្អតលាស់ រីកចំរើនគ្រប់ផ្នែក ប្រកបដោយគុណភាពព្រមៗគ្នា រវាងប្រាជ្ញា ស្មារតី សញ្ចេតនា និង រូបរាងកាយ ។ ដើម្បីសំរេចទិសដៅនេះ សាលារៀនត្រូវ

បំពេញភារកិច្ចបណ្តុះបណ្តាលពលរដ្ឋថ្លៃថ្នូរ ម្ចាស់ការទុកចិត្តលើខ្លួនឯង មានចំនេះដឹង និងបំនិន មានសីលធម៌ សាមគ្គីឯកភាពជាតិ មានមនសិកាស្នេហាជាតិ គោរពច្បាប់ សិទ្ធិមនុស្ស រួមរស់ដោយរក្សាតម្លៃវប្បធម៌ អរិយធម៌ជាតិ មានស្មារតីទទួលខុសត្រូវ និងសមត្ថភាពកសាងសុខុមាលភាពគ្រួសារ និង សង្គម ។

ការអប់រំចំនេះទូទៅ ត្រូវខិតខំឆ្លើយតបនឹងទិសដៅខាងលើ ក្នុងការបណ្តុះបណ្តាលចំនេះដឹង បំនិន តម្លៃបុគ្គលិកលក្ខណៈ ពិសោធន៍ការងារ និងសកម្មភាពមានប្រយោជន៍ដល់សិស្សដទៃទៀត និងដល់សង្គម ។

ស្របទៅតាមវ័យរបស់កុមារ ទិសដៅនៃការអប់រំនៅបឋមសិក្សា គឺត្រូវយកចិត្តទុកដាក់បណ្តុះបណ្តាលបុគ្គលិកលក្ខណៈល្អ លើកកំពស់សមត្ថភាពផ្លូវកាយ ចិត្ត ប្រាជ្ញាដល់កុមារ ដោយធានាអោយគេអាចប្រើប្រាស់បាននូវចំនេះដឹងមូលដ្ឋាន (អាន សរសេរ និយាយ ស្តាប់ នព្វន្ត) មានសុខភាពល្អ ចេះដោះស្រាយបញ្ហាចំពោះមុខ ចូលចិត្តរៀនសូត្រ និងធ្វើពលកម្មដើម្បីអោយក្លាយជាមនុស្សមានប្រយោជន៍សំរាប់សហគមន៍ អាចទទួលការអប់រំមុខរបរផ្សេងៗ រឺ អាចបន្តការសិក្សាទៅថ្នាក់លើទៀតបាន ។

ឯទិសដៅអប់រំនៅមធ្យមសិក្សា គឺពង្រីងបន្ថែមនូវចំនេះដឹង និងបំនិនដែលកុមារបានទទួលរួចហើយនៅបឋមសិក្សា ដោយធានាពង្រីកផ្នែកសេរីភាពខាងគំនិតបញ្ចេញយោបល់ និងអធ្យាស្រ័យ ហើយបង្កអោយមានការអភិវឌ្ឍន៍ព្រមៗគ្នា ខាងកោសល្យ ឥរិយាបថ តម្លៃ គំនិតច្នៃប្រឌិត សីលធម៌សង្គម និង សិល្បៈ សោភ័ណ ។

រួមសេចក្តីមក ក្រោយពីទទួលការអប់រំមូលដ្ឋាន កុមារអាចក្លាយជាមនុស្សពេញលេញអាចរស់នៅក្នុងសង្គម រឺ អាចបន្តការសិក្សាទៅថ្នាក់លើទៀតបានតាមតំរូវការ ។

------ * ------

## ពិសោធន៍វិទ្យាសាស្ត្រ

* * * * *

សូមលោកគ្រូ-អ្នកគ្រូ ធ្វើការពិសោធន៍ដូចខាងក្រោម :

- យកផ្លែក្រូចឆ្មារមួយដាក់ក្នុងកែវ មានទឹកពេញ ។ ផ្លែក្រូចនឹងធ្លាក់ទៅនៅឯបាតកែវ ។
- ដាក់អំបិលបន្តិចម្តងៗ ទៅក្នុងទឹក ។ ផ្លែក្រូចឆ្មារកំរើក ហើយអណ្តែតឡើងពីបាតកែវមកលើវិញ ។

**សំនួរ** : តើដោយមូលហេតុអ្វី បានជាផ្លែក្រូចអណ្តែតឡើងមកលើវិញ ?

(ចំលើយត្រឹមត្រូវនឹងផ្សាយក្នុងទស្សនាវដ្តី តែមិនបានជូនរង្វាន់ទេ ។)



# ស្ថានភាពសពចាប់ពីខែមករា
# ដល់ចុងខែ កញ្ញា ឆ្នាំ ២០០០

| ខែ | សពសមាជិក | សពគូស្រករ ( ប្ដី ឬ ប្រពន្ធ ) |
|---|---|---|
| មករា | ៣៦ នាក់ | ១៨ នាក់ |
| កុម្ភៈ | ៣៣ នាក់ | ២៤ នាក់ |
| មីនា | ៣៥ នាក់ | ២០ នាក់ |
| មេសា | ៣៤ នាក់ | ២២ នាក់ |
| ឧសភា | ៣៥ នាក់ | ២០ នាក់ |
| មិថុនា | ៣៣ នាក់ | ២៤ នាក់ |
| កក្កដា | ៣៦ នាក់ | ១៨ នាក់ |
| សីហា | ៣៦ នាក់ | ១៨ នាក់ |
| កញ្ញា | ៣២ នាក់ | ២៦ នាក់ |
| **សរុប** | ៣១០ នាក់ | ១៩០ នាក់ |

**កំនត់សំគាល់**

✱ មកទល់ដំណាច់ឆ្នាំ ១៩៩៩ សមាជិកស្លាប់មាន ចំនួន ១៧៣០ នាក់

✱ ចាប់ពីខែ មករា ដល់ខែ កញ្ញា ឆ្នាំ ២០០០ សមាជិក ស្លាប់មានចំនួន ៣១០ នាក់

សរុបសមាជិកស្លាប់ទាំងអស់ដល់ដំណាច់ខែ កញ្ញា ឆ្នាំ ២០០០មានចំនួន ២០៤០ នាក់

✱ មកទល់ដំណាច់ចុងឆ្នាំ ១៩៩៩ គូស្រករសមាជិកស្លាប់មានចំនួន ១២០៦ នាក់

✱ ចាប់ពីខែ មករា ដល់ខែ កញ្ញា ឆ្នាំ ២០០០ សមាជិក គូស្រករដែលស្លាប់មានចំនួន ១៩០ នាក់

សរុបសមាជិកគ្រួសារស្លាប់ដល់ចុងខែ កញ្ញា ឆ្នាំ ២០០០ មានចំនួន ១៣៩៦ នាក់